00568517

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 28 / 07 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

D310/1/3

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

**តាងនាមប្រជារាស្ត្រខ្មែរ និងតាងនាមអង្គការសហប្រជាជាតិ ដោយអនុលោមតាមច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ**

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ៥២)

ចំពោះមុខ: **ចៅក្រម ប្រាក់ គឹមសាន, ប្រធាន**
**ចៅក្រម** Rowan DOWNING
**ចៅក្រម ន័យ ថុល**
**ចៅក្រម** Catherine MARCHI-UHEL
**ចៅក្រម ហួត វុទ្ធី**

កាលបរិច្ឆេទ: ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១០

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 28 / 07 / 2010
ម៉ោង (Time/Heure): 13:15
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

---

**សាធារណៈ(ដោយកោសលុប)**
**សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ប្រឆាំងនឹងដីកាសម្រេចបដិសេធសំណើសុំសម្ភាសន៍បុគ្គលដូចរាយនាមនៅក្នុងសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរស្តីពីការបាត់ខ្លួនដោយបង្ខំ និងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ**

---

**សហព្រះរាជអាជ្ញា**
ជា លាង
Andrew CAYLEY

**ជនត្រូវចោទ**
នួន ជា
ខៀវ សំផន
អៀង សារី
អៀង ធីរិទ្ធ
កាំង ហ្គេកអ៊ាវ ហៅ "ឌុច"

អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE * E.C.C.C * C.E.T.C

០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ៥២)

លេខ/No. D310/1/3

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

គីម ម៉េងឃី

ម៉ុច សុវណ្ណារី

Martine JACQUIN
Philippe CANONNE
Fabienne TRUSSES-NAPROUS
Elizabeth-Joelle RABESANDRATANA
Annie DELAHAIE

នី ចាន់ឌី

ឡោ ជុនធី

Silke STUDZINSKY

គង់ ពិសី

ហុង គឹមសួន

Pierre-Olivier SUR

យុង ផានិត

ស៊ីន សុវ៉ន

Mahdev MOHAN
NGUYEN Lyma
Marie GUIRAUD
Patrick BAUDOIN
Olivier BAHOUGNE
Julien RIVET
Emmanuel ALTIT
Maria Stefania CATALETA

គង់ ហេង

សំ សុគង់

សុខ សំអឿន

Charlotte PLANTIN
Pascal AUBOIN
Jan Ernest RASSEK

ជេត វណ្ណលី

ពេជ អង្គ

**សហមេធាវីការពារក្តីជនត្រូវចោទ**

សុន អរុណ    Michiel PESTMAN
Victor KOPPE
Andrew IANUZZI

ស សូវ៉ាន    Jacques VERGÈS
Philippe Gréciano

ផាត់ ពៅស៊ាង    Diana ELLIS

អាង ឧត្តម    Michael G. KARNAVAS

**សហចៅក្រមស៊ើបអង្កេត**

យូ ប៊ុនឡេង    Marcel LEMONDE

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួល"បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ប្រឆាំងនឹងដីកាបដិសេធសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរសាក្សី ដែលមានឈ្មោះនៅក្នុងសំណើសុំឱ្យមានកិច្ចស៊ើបសួរលើការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ"[១] ដែលសហមេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី ("បណ្តឹងឧទ្ធរណ៍" និងដើមបណ្តឹងឧទ្ធរណ៍) បានដាក់ប្តឹងនៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១០ ប្រឆាំងនឹង"ដីការបស់សហចៅក្រមស៊ើបអង្កេត ("ស.ច.ស") ស្តីពីសំណើសុំសម្ភាសន៍បុគ្គលដែលមានឈ្មោះក្នុងសំណើសុំបំពេញកិច្ចស៊ើបសួរទាក់ទងការរៀបការដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ"[២] ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ ("ដីកាសម្រេចដែលត្រូវបានជំទាស់")។

## I. **ប្រវត្តិនីតិវិធី**

១. នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៩ ស.ច.ស បានចេញដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ("ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ")[៣] ទៅឱ្យសហព្រះរាជអាជ្ញាដើម្បីស្នើសុំ (១) យោបល់លើការទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួនបួន ពីបុគ្គលដែលបានអះអាងថា អង្គការបានបង្ខំពួកគេឱ្យរៀបការ ដោយករណីមួយចំនួន ការរៀបការដោយបង្ខំនោះធ្វើឡើងក្នុងពេលតំណាលគ្នាជាមួយអ្នកដទៃទៀតរាប់សិបគូ ហើយពួកគេទទួលរងការគម្រាមសម្លាប់ចោលជាចំហ ប្រសិនបើពួកគេបដិសេធមិនព្រមមានទំនាក់ទំនងផ្លូវភេទជាមួយប្តី/ប្រពន្ធរបស់ពួកគេ[៤] ហើយនឹង (២) ប្រសិនបើចាំបាច់ ស្នើសុំចេញដីកាសន្និដ្ឋានឱ្យស៊ើបសួរបន្ថែម។ ស.ច.ស បានកត់សម្គាល់ថា ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យ

---

[១] បណ្តឹងឧទ្ធរណ៍របសដើមបណ្តឹងរដ្ឋប្បវេណី ជំទាស់ដីកាបដិសេធសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរសាក្សី ដែលមានឈ្មោះនៅក្នុងសំណើសុំឲ្យមានកិច្ចស៊ើបសួរលើការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១០ ឯកសារ D310/1/1 ("បណ្តឹងឧទ្ធរណ៍)។

[២] ដីកាស្តីពីសំណើសុំសម្ភាសន៍បុគ្គលដែលមានឈ្មោះក្នុងសំណើសុំបំពេញកិច្ចស៊ើបសួរទាក់ទងការរៀបការដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ D310 ("ដីកាដែលត្រូវបានជំទាស់")។

[៣] ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៩ ឯកសារ D146 ("ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ")។

[៤] ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ទំព័រ ១-២ យោងទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីលេខ 08-[redacted]01937; 08-[redacted]-01938; 08-[redacted]-01939 និង 08-[redacted]-02059។

ស៊ើបសួរ")[៥] និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០៨ ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីមួយ")[៦] មិនបាននិយាយយោងលើគោលនយោបាយរបស់របបនេះត្រង់ទិដ្ឋភាពជាក់លាក់មួយនេះឡើយ ហើយបានបញ្ជាក់ថា សាក្សីជាច្រើន រួមទាំងដើមបណ្តឹងរដ្ឋប្បវេណីចំនួនបួនរូប[៧] បានរៀបរាប់អំពីហេតុការណ៍ ដែលបានកើតឡើងស្រដៀងគ្នា[៨]។

២. នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៩ សហព្រះរាជអាជ្ញាបានដាក់ "ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យរបស់សហចៅក្រមស៊ើបអង្កេត និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម" ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីពីរ")[៩] ដោយក្នុងនោះស្នើសុំ និងអនុញ្ញាតឱ្យ ស.ច.ស បើកការស៊ើបសួរលើអង្គហេតុដែលដើមបណ្តឹងចំនួនប្រាំនាក់បានដាក់ប្តឹងចោទប្រកាន់ថា ពួកគេត្រូវបានកម្មាភិបាលខ្មែរក្រហមចាប់បង្ខំឱ្យរៀបការ និងមានទំនាក់ទំនងផ្លូវភេទ នៅក្នុងខេត្តកំពត[១០] និងខេត្ត[១១]តាកែវ[១២]។ សហព្រះរាជអាជ្ញាក៏បាន

---

[៥] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ឯកសារ D3 ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ")។

[៦] សេចក្តីសន្និដ្ឋានបន្ថែម ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០៨ ឯកសារ D83 ("សេចក្តីសន្និដ្ឋានបន្ថែម លើកទី១")។

[៧] ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ទំព័រ ២ យោងឯកសារ D22/17, D22/31, D22/33 និង 08-[redacted]-02207, D22/34។

[៨] ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ទំព័រ ២។

[៩] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងដីកាបញ្ជូនរឿងទៅពិនិត្យរបស់សហចៅក្រមស៊ើបអង្កេតនិងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៩ ឯកសារ D146/3 ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទី២")។

[១០] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទី២ កថាខណ្ឌ ២(ក) យោងទៅឯកសារ 08-[redacted]-01937; 08-[redacted]-01938 និង D22/33។

[១១] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទី២ កថាខណ្ឌ ២(ខ) យោងទៅឯកសារ 08-[redacted]-01939 និង D22/31.

[១២] សហព្រះរាជអាជ្ញាបានពិចារណាបន្ថែមទៀតថា ចំពោះដើមបណ្តឹងចំនួនបីនាក់ បណ្តឹងរបស់ពួកគេបានប្តឹងជាចំបងលើការបាត់ខ្លួន និងការសម្លាប់សាច់ញាតិ។ សហព្រះរាជអាជ្ញាក៏បានពិចារណាថា ចំពោះបណ្តឹងទីមួយ ការស៊ើបអង្កេតលើការរៀបការដោយបង្ខំ ឬ ទំនាក់ទំនងផ្លូវភេទដោយបង្ខំ មិនចាំបាច់ធ្វើឡើងឡើយ (ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទី២ កថាខណ្ឌ ៣ ទាក់ទងនឹងឯកសារ D22/170)។ ដើមបណ្តឹងទីពីរចោទប្រកាន់អំពីការរៀបការដោយបង្ខំ ប៉ុន្តែមិនបានចោទប្រកាន់អំពីទំនាក់ទំនងផ្លូវភេទដោយបង្ខំឡើយ។ ដូច្នេះ ស.ច.ស គួរសម្រេចលើពាក្យសុំរបស់ដើមបណ្តឹងមួយនេះ ដោយផ្អែកលើ *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីជំទាស់[illegible]សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ សាក្សីដែលមានឈ្មោះនៅក្នុងសំណើសុំឱ្យមានកិច្ចស៊ើបសួរលើ[illegible]ដោយបង្ខំនិងការបាត់ខ្លួនដោយបង្ខំ*

E.C.C.C * C.E.T.C
PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

អនុញ្ញាតឱ្យ ស.ច.ស បើកការស៊ើបសួរលើអង្គហេតុដទៃៗទៀត ប្រសិនបើអង្គហេតុទាំងនោះជួយកំណត់បានពី (ក) ធាតុផ្សំខាងយុត្តាធិការ ចាំបាច់ដើម្បីបញ្ជាក់បានថាតើបញ្ហាខាងអង្គហេតុដូចដែលបានយោងនៅក្នុងកថាខណ្ឌទីពីរនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីពីរជាបទឧក្រិដ្ឋក្នុងយុត្តាធិការរបស់ អ.វ.ត.ក ដែរឬទេ ឬ (ខ) ទម្រង់នៃការទទួលខុសត្រូវរបស់ នួន ជា អៀង សារី ខៀវ សំផន ឬ អៀង ធីរិទ្ធ ទាក់ទិននឹងបញ្ហាទាំងនេះ[១៣]។

៣. នៅថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០០៩ សហព្រះរាជអាជ្ញាបានដាក់ "សេចក្តីអនុញ្ញាតបន្ថែម ដោយអនុលោមតាមចម្លើយតបរបស់សហព្រះរាជអាជ្ញាចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៩ ទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យរបស់សហចៅក្រមស៊ើបអង្កេត និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម" ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីបី")[១៤]។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីបីនេះបានអនុញ្ញាតឱ្យស.ច.ស តាមដែលខ្លួនកំណត់ថាសមស្រប ពិចារណា និងធ្វើការស៊ើបសួរបន្ថែមទៀតទៅលើឧប្បត្តិហេតុនានា ដូចបានចោទប្រកាន់អំពីអាពាហ៍ពិពាហ៍ដោយបង្ខំ និងសម្ព័ន្ធភាពផ្លូវភេទ ក្រៅអំពីឧប្បត្តិហេតុនានាដូចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីពីរ[១៥]។

៤. នៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៩ សហព្រះរាជអាជ្ញាបានដាក់ "សេចក្តីថ្លែងការណ៍បន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងនឹង"ចម្លើយតបចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៩ ទៅនឹងដីកាសន្និដ្ឋានបញ្ជូនសំណុំរឿងទៅពិនិត្យរបស់សហចៅក្រមស៊ើបអង្កេតនិងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

---

ការចោទប្រកាន់អំពីការសម្លាប់ឪពុករបស់គេ (ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមលើកទី២ កថាខណ្ឌ៤ ទាក់ទងនឹងពាក្យសុំលេខ 08-[redacted]-02059)។ ដើមបណ្តឹងទីបី ទំនងជាមិនបានចោទប្រកាន់អំពីទំនាក់ទំនងផ្លូវភេទដោយបង្ខំឡើយ ហើយវាមិនមានលក្ខណៈច្បាស់លាស់ថាតើដើមបណ្តឹងនេះបានចូលរួមនៅក្នុងការរៀបការដោយបង្ខំនេះដែរឬទេ ដូច្នេះ បណ្តឹងរបស់គេស្ថិតនៅក្រៅវិសាលភាពនៃការស៊ើបអង្កេតលើការរៀបការដោយបង្ខំ និងទំនាក់ទំនងផ្លូវភេទដោយបង្ខំ (សេចក្តីសន្និដ្ឋានបន្ថែមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៥ ទាក់ទងនឹងពាក្យសុំលេខ 08-[redacted]-02207)។

[១៣] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមលើកទីពីរ កថាខណ្ឌ ៦។

[១៤] សេចក្តីអនុញ្ញាតបន្ថែមរបស់សហព្រះរាជាអាជ្ញា ចំពោះចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យរបស់សហចៅក្រមស៊ើបអង្កេតនិងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ D146/4 ("ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមលើកទីបី")។

[១៥] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមលើកទីបី កថាខណ្ឌ ៣។

00568522



បន្ថែម" ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីបួន")[១៦]។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីបួននេះលើកឡើងថា អនុលោមតាមវិធាន ៥៣(១)(ខ) និង (គ) នៃវិធានផ្ទៃក្នុង ឧប្បត្តិហេតុដែលបានចោទប្រកាន់អំពីអាពាហ៍ពិពាហ៍ដោយបង្ខំ និងទំនាក់ទំនងផ្លូវភេទដែល ស.ច.ស ត្រូវបានអនុញ្ញាតឱ្យបំពេញកិច្ចស៊ើបសួរនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីពីរ អាចត្រូវបានចាត់ថា ជាបទចោទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ពោលដូចជាការរំលោភផ្លូវភេទ ឬអំពើអមនុស្សធម៌ផ្សេងទៀត ដែលអាចដាក់ទណ្ឌកម្មបានតាមមាត្រា ៥ មាត្រា ២៩(ថ្មី) និងមាត្រា ៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើតឱ្យមាន អ.វ.ត.ក។ ដើម្បីបង្ហាញថាអំពើទាំងនេះជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ យើងចាំបាច់ត្រូវតែបង្ហាញថា អំពើបែបដូច្នោះត្រូវបានប្រព្រឹត្តជាផ្នែកមួយនៃការវាយប្រហារជាទូទៅ ឬជាប្រព័ន្ធ សំដៅប្រឆាំងទៅលើប្រជាជនស៊ីវិល ដោយមូលហេតុ ជាតិ នយោបាយ ជាតិពិន្ទុ ពូជសាសន៍ ឬ សាសនាណាមួយ[១៧]។

៥. នៅចន្លោះថ្ងៃទី២ ខែកក្កដា ឆ្នាំ២០០៩ និងថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៩ ដើមបណ្តឹងឧទ្ធរណ៍បានដាក់សំណើសុំបំពេញកិច្ចស៊ើបសួរចំនួនបី៖

(១) "សំណើសុំកិច្ចស៊ើបអង្កេតរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងបទល្មើសនៃការបាត់ខ្លួនមនុស្សដោយបង្ខំ" ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ និងបានដាក់នៅថ្ងៃទី២ ខែកក្កដា ឆ្នាំ២០០៩ ("សំណើលើកទីមួយ")[១៨]។ សំណើលើកទីមួយនេះស្នើសុំ "កិច្ចស៊ើបអង្កេតបន្ថែមចំពោះអង្គហេតុ ដែលបានលើកឡើងនៅក្នុងចម្លើយរបស់សាក្សីផ្សេងៗដែលបានដាក់ជូនដោយ ក.ស.ច.ស" ក្រោមវិសាលភាពនៃការបាត់ខ្លួនមនុស្សដោយបង្ខំ។ សំណើទាំងនេះរួមមាន កំណត់អត្តសញ្ញាណ និងសាកសួរអតីតកម្មាភិបាលខ្មែរក្រហមដែលជាប់ពាក់ព័ន្ធ ឬ ដឹងព័ត៌មានអំពីការចាប់ខ្លួនជនរងគ្រោះដែលបានបាត់ខ្លួន និងបុគ្គលទាំងឡាយ ដែលបានបាត់សាច់ញាតិរបស់ខ្លួន[១៩]។

---

[១៦] សេចក្តីថ្លែងការណ៍របស់សហព្រះរាជអាជ្ញាទាក់ទងនឹងចម្លើយតប ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៩ ទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យរបស់សហចៅក្រមស៊ើបអង្កេត និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ D146/5 ("ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមលើកទីបួន")។

[១៧] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមលើកទីបួន កថាខណ្ឌ ៣។

[១៨] សំណើរួមរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីសុំបំពេញកិច្ចស៊ើបសួរទាក់ទិននឹងបទល្មើសនៃការបាត់ខ្លួនមនុស្សដោយបង្ខំ ចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ២០០៩ ឯកសារ D180 ("សំណើលើកទី១")។

[១៩] សំណើលើកទី១ កថាខណ្ឌ ១, ២៧។




PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

00568523



(២) "សំណើលើកទីពីរសុំឱ្យមានកិច្ចស៊ើបសួរស្ដីពីអាពាហ៍ពិពាហ៍ដោយបង្ខំ និងទំនាក់ទំនងផ្លូវភេទដោយបង្ខំ" ចុះថ្ងៃទី១៥ ខែកក្កដា និងបានដាក់នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២00៩ ("សំណើលើកទីពីរ")[២0]។ សំណើលើកទីពីរបានស្នើសុំឱ្យ ស.ច.ស "(ក) បើកកិច្ចស៊ើបអង្កេតឱ្យបានពេញលេញមួយ ទៅលើអត្ថិភាពនៃឧក្រិដ្ឋកម្មនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ តួយ៉ាងដូចជា ការរំលោភផ្លូវភេទ ការដាក់មនុស្សជាទាសករ និងការមានផ្ទៃពោះដោយបង្ខំ[២១] (ខ) ស៊ើបអង្កេតតាមការស្នើសុំរបស់សហព្រះរាជអាជ្ញា លើការចោទប្រកាន់របស់ឈ្មោះ [redacted]"[២២] និងកំណត់អត្តសញ្ញាណ និងសាកសួរ អ្នកតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី "ដែល ក.ស.ព បានប្រកាសថាពួកគេមានសារតាពុំច្បាស់លាស់ និងស៊ើបអង្កេតការចោទប្រកាន់របស់ពួកគេអំពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ហើយប្រសិនបើការរួមសង្វាសត្រូវបានបង្គាប់ដោយផ្ទាល់ ស៊ើបអង្កេតលើវិធីនៃការតាមដាននូវយប់ដំបូង សម្ព័ន្ធភាពប្ដីប្រពន្ធក្នុងគ្រាបន្ទាប់ និងផលប៉ះពាល់ផ្លូវចិត្តចំពោះការរួមសង្វាស"[២៣] និង (គ) កំណត់អត្តសញ្ញាណ និងសាកសួរសាក្សីដែលមានឈ្មោះទាំង [redacted][២៤]។

(៣) "សំណើលើកទីបួនរបស់សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីសុំឱ្យមានកិច្ចស៊ើបសួរ ពាក់ព័ន្ធអាពាហ៍ពិពាហ៍ដោយបង្ខំ និងឧក្រិដ្ឋកម្មផ្លូវភេទ" ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២00៩ និងដាក់នៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ២00៩ ("សំណើលើកទីបី")[២៥]។ សំណើលើកទីបីនេះបានស្នើសុំឱ្យ ស.ច.ស ផ្ដោតការសាកសួរសាក្សីលើ (ក) ការរៀបចំអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ "ជាទ្រង់ទ្រាយធំ" នៅទូទាំងប្រទេស ព្រមទាំងបញ្ហានានាដែលបានដាក់មក តាមរយៈរចនាសម្ព័ន្ធរបស់ខ្មែរក្រហម ពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ ការដាក់ទោសចំពោះការប្រកែកមិនធ្វើតាមការបញ្ជាទាំងនោះ ព្រមទាំងការចេញ"បញ្ជាដោយផ្ទាល់ និងដោយបង្ខំ របស់ខ្មែរក្រហមឱ្យប្ដីប្រពន្ធរួមរក្សជាមួយគ្នា ក្រោយពីបានរៀបអាពាហ៍ពិពាហ៍រួចហើយ"[២៦] (ខ) អ្វីដែលត្រូវបានចាត់ទុកថា "ខុសសីលធម៌" និងថាតើការខុសសីលធម៌នេះរួមទាំង

---

[២0] សំណើលើកទី២ សុំឱ្យមានកិច្ចស៊ើបសួរ ស្ដីពីអាពាហ៍ពិពាហ៍ដោយបង្ខំ និងទំនាក់ទំនងផ្លូវភេទដោយបង្ខំ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២00៩ ឯកសារ D188 ("សំណើលើកទីពីរ")។

[២១] សំណើលើកទីពីរ កថាខណ្ឌ ៣១(ក)។

[២២] សំណើលើកទីពីរ កថាខណ្ឌ ៣១(ខ)។

[២៣] *ដូចដើងទំព័រខាងលើ។*

[២៤] សំណើលើកទីពីរ កថាខណ្ឌ ៣១(គ)។

[២៥] សំណើលើកទីបួនរបស់សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីសុំឱ្យមានកិច្ចស៊ើបសួរ ពាក់ព័ន្ធអាពាហ៍ពិពាហ៍ដោយបង្ខំ និងឧក្រិដ្ឋកម្មផ្លូវភេទ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២00៩ ឯកសារ D268 ("សំណើលើកទីបី")។

[២៦] សំណើលើកទីបី កថាខណ្ឌ ៤។



PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRELIMINAIRE

បទឧក្រិដ្ឋទាក់ទងនឹងផ្លូវភេទនានាដែរឬយ៉ាងណា ព្រមទាំងកម្រិតនៃការកើតមានបទឧក្រិដ្ឋ និងថាតើការត្រួតពិនិត្យព្រហ្មចារីជាការអនុវត្តទូទៅនៅក្នុងរបបខ្មែរក្រហមដែរឬទេ[២៧]។ ដើមបណ្ដឹងឧទ្ធរណ៍ក៏បានស្នើសុំឱ្យអ្នកជំនាញទាំងបីជួយការងារក្នុងការបំពេញកិច្ចស៊ើបសួរផងដែរ[២៨] ហើយដើមបណ្ដឹងឧទ្ធរណ៍ក៏បានស្នើសុំឱ្យមានមន្ត្រីស៊ើបអង្កេតនារីដែលទទួលបានការបណ្ដុះបណ្ដាលពីយេនឌ័រ ជាអ្នកសាកសួរសាក្សីដែលមានឈ្មោះទាំង [redacted] រូប អំពីហេតុការណ៍នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងខេត្តស្វាយរៀង ខេត្តកំពង់ចាម ខេត្តកណ្ដាល ខេត្តបាត់ដំបង ខេត្តកំពង់ធំ ខេត្តស្ទឹងត្រែង រួមទាំងខេត្តដទៃទៀត[២៩] ព្រមទាំងសាកសួរសាក្សីទាំង [redacted] រូប ដែលបានរៀបរាប់អំពីបទឧក្រិដ្ឋពាក់ព័ន្ធនឹងការរំលោភផ្លូវភេទ[៣០]។

៦. នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០ ស.ច.ស បានចេញដីកាសម្រេចដែលត្រូវបានជំទាស់ ដែលដីកាសម្រេចនេះបានបដិសេធសំណើសុំសាកសួរបុគ្គលមួយរូបក្នុងចំណោមបុគ្គលទាំងឡាយ ដែលបានស្នើសុំឱ្យសាកសួរនៅក្នុងសំណើលើកទីពីរ និងបុគ្គលចំនួន [redacted] រូប ក្នុងចំណោមបុគ្គលទាំងឡាយដែលបានស្នើសុំឱ្យសាកសួរនៅក្នុងសំណើលើកទីបី[៣១]។ បន្ថែមលើចំណុចនេះ ដីកាសម្រេចនេះបាន (១) កត់សម្គាល់ថា បុគ្គលទាំងឡាយដែលនៅសល់ ដូចមានឈ្មោះនៅក្នុងសំណើលើកទីពីរ និងសំណើលើកទីបី ត្រូវបាន ក.ស.ច.ស សាកសួររួចហើយ ដូច្នេះសម្រេចបដិសេធសំណើសុំសាកសួរពួកគេបន្ថែម[៣២], (២) ទទួលយកជាគោលការណ៍នូវសំណើសុំសាកសួរបុគ្គលមួយរូបក្នុងចំណោមបុគ្គលទាំងឡាយ ដែលមានឈ្មោះនៅក្នុងសំណើលើកទីមួយ ប៉ុន្តែយល់ឃើញថា ការបំពេញកិច្ចស៊ើបសួរលើបុគ្គលនេះមិនអាចធ្វើទៅបាន[៣៣], និង (៣)

---

[២៧] សំណើលើកទីបី កថាខណ្ឌ ៥។

[២៨] សំណើលើកទីបី កថាខណ្ឌ ៧ យោងទៅលើលោកស្រី [redacted], បណ្ឌិត [redacted] និងបណ្ឌិត [redacted]។

[២៩] សំណើលើកទីបី កថាខណ្ឌ ៨ (ក) និង (ឃ)។

[៣០] សំណើលើកទីបី កថាខណ្ឌ ៨ (ខ)។

[៣១] ដីកាដែលត្រូវបានជំទាស់ កថាខណ្ឌ ១៩។

[៣២] ដីកាដែលត្រូវបានជំទាស់ កថាខណ្ឌ ២០។

[៣៣] ដីកាដែលត្រូវបានជំទាស់ កថាខណ្ឌ ២១។

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

សម្រេចបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងសំណើដែលបានស្នើសុំសាកសួរបុគ្គលទាំងឡាយដែលនៅសល់ ដូចមានរៀបរាប់នៅក្នុងសំណើលើកទីមួយ[៣៤]។

៧. ដីកាសម្រេចដែលត្រូវបានជំទាស់ ត្រូវបានជូនដំណឹងដល់សហមេធាវីតំណាងអ្នកដាក់ពាក្យតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជាភាសាអង់គ្លេសនៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០១០ និងជាភាសាខ្មែរនៅថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១០។ ដើមបណ្តឹងឧទ្ធរណ៍បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០១០ អនុលោមតាមវិធាន ៧៥(១) នៃវិធានផ្ទៃក្នុង ហើយសារណាបណ្តឹងឧទ្ធរណ៍បានដាក់នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១០ ក្នុងរយៈពេលកំណត់ដូចមានចែងនៅក្នុងវិធាន ៧៥(៣) នៃវិធានផ្ទៃក្នុង។

## II. សេចក្តីសង្ខេបនៃបណ្តឹងឧទ្ធរណ៍

៨. បណ្តឹងឧទ្ធរណ៍បានដាក់ដោយផ្អែកលើមូលដ្ឋានដូចមានចែងនៅក្នុងវិធាន ៧៤(៤)(ក) នៃវិធានផ្ទៃក្នុង[៣៥] ហើយបានចោទប្រកាន់ថា ដីកាសម្រេចដែលត្រូវបានជំទាស់មានកំហុសអង្គច្បាប់ និងផ្អែកលើការបកស្រាយមិនត្រឹមត្រូវលើច្បាប់ជាធរមាន នៅពេលដីកានេះសម្រេចបដិសេធសំណើទាំងឡាយចោល។ បណ្តឹងឧទ្ធរណ៍បានរៀបរាប់កំហុសចំនួនបួន ដែល ស.ច.ស. បានប្រព្រឹត្ត ហើយបានអះអាងថា កំហុសទាំងបួននោះធ្វើឱ្យសេចក្តីសម្រេចមិនត្រឹមត្រូវ ដោយសារបានលើកឡើងថា (១) បុគ្គលដែលត្រូវបានស្នើសុំឱ្យសាកសួរតាមសំណើលើកទីមួយ សំណើលើកទីពីរ និងសំណើលើកទីបី ត្រូវបានសាកសួររួចហើយ[៣៦], (២) អង្គហេតុដែលបានស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរ មិនស្ថិតនៅក្នុងវិសាលភាពនៃការស៊ើបអង្កេត ឬសំណើទាំងនេះមិនបានបង្ហាញឱ្យបានច្បាស់លាស់ថា អង្គហេតុនោះស្ថិតនៅក្នុងវិសាលភាពនៃការស៊ើបអង្កេត[៣៧], (៣) ស.ច.ស មិនអាចកំណត់អត្តសញ្ញាណ និងស្វែងរកបុគ្គលទាំងឡាយដែលបានស្នើសុំឱ្យមានការសាកសួរ[៣៨]។

---

៣៤ ដីកាដែលត្រូវបានជំទាស់ កថាខណ្ឌ ២២។

៣៥ បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១១។

៣៦ បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១២-២៩។

៣៧ បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣០-៤៣។

៣៨ បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៤៤-៤៩។

PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE

និង (៤) ការសាកសួរបុគ្គលដែលបានស្នើឡើងនេះ នឹងមិនជួយសម្រួលដល់ការប្រមូលភស្តុតាងឡើយ[៣៩]។ បណ្តឹងឧទ្ធរណ៍បានបន្តចោទប្រកាន់ទៀតថា ដីកាសម្រេចដែលត្រូវបានជំទាស់នោះផ្អែកលើការសន្និដ្ឋានមិនត្រឹមត្រូវដោយច្បាស់ក្រឡែតលើអង្គហេតុ នៅពេលសម្រេចបដិសេធមិនទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមួយរូប[៤០]។ ដើមបណ្តឹងឧទ្ធរណ៍ស្នើសុំឱ្យអង្គបុរេជំនុំជម្រះច្រានចោលដីកាសម្រេច ដែលត្រូវបានជំទាស់ ដោយផ្អែកលើមូលដ្ឋានថាដីកាសម្រេចមានកំហុសអង្គហេតុ និងអង្គច្បាប់ដូចដែលបានលើកឡើងខាងលើ ហេតុដូច្នេះអង្គបុរេជំនុំជម្រះគួរបង្គាប់ឱ្យ ស.ច.ស បំពេញកិច្ចស៊ើបសួរតាមសំណើសុំវិញ[៤១]។

៩. ភាគីមិនបានដាក់សេចក្តីសន្និដ្ឋានតបទៅនឹងបណ្តឹងឧទ្ធរណ៍ឡើយ។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ដើមបណ្តឹងឧទ្ធរណ៍មិនបានស្នើសុំឱ្យបើកសវនាការជាសាធារណៈឡើយ ហេតុដូច្នេះអង្គបុរេជំនុំជម្រះយល់ឃើញថា វាជាការសមស្របដែលបណ្តឹងឧទ្ធរណ៍នេះនឹងយកមកសម្រេចដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរដែលដាក់ជូនដោយដើមបណ្តឹងឧទ្ធរណ៍តែប៉ុណ្ណោះ។

## III. ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍

១០. វិធាន៧៤(៤)(ក) នៃវិធានផ្ទៃក្នុង ផ្តល់សិទ្ធិដល់ដើមបណ្តឹងរដ្ឋប្បវេណីប្តឹងឧទ្ធរណ៍នៅចំពោះមុខអង្គបុរេជំនុំជម្រះ ប្រឆាំងនឹងដីការបស់ ស.ច.ស ដែលបានសម្រេចបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរ។ អនុលោមតាមវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង នៅគ្រប់ពេលវេលានៃការស៊ើបសួរ ដើមបណ្តឹងរដ្ឋប្បវេណីអាចស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតចេញដីកា ឬបំពេញកិច្ចស៊ើបសួរណាមួយដែលខ្លួនយល់ឃើញថាមានប្រយោជន៍ដល់ការស៊ើបសួរ។ អង្គបុរេជំនុំជម្រះពិចារណាឃើញថា វិធានទាំងពីរអាចអនុវត្តចំពោះអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ក៏ដូចជាដើមបណ្តឹងរដ្ឋប្បវេណីបានលើកលែងតែសេចក្តីសម្រេចចុងក្រោយ ប្រកាសមិនទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។

---

[៣៩] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៥០-៥៩។

[៤០] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៦០-៦២ យោងទៅលើ [redacted]។

[៤១] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៦២។

១១. បន្ថែមលើវិធានទាំងនេះ វិធាន ៥៥(៣) នៃវិធានផ្ទៃក្នុង កម្រិតឱ្យ ស.ច.ស ស៊ើបអង្កេតលើតែអង្គហេតុថ្មីៗ ដែលជាស្ថានទម្ងន់ទោស ពាក់ព័ន្ធនឹងដីកាសន្និដ្ឋានដែលមានស្រាប់ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាតែប៉ុណ្ណោះ។ នៅពេលពិនិត្យវិធានទាំងពីរនេះរួមគ្នា វិធាន ៥៥(៣) និងវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុងបង្ហាញថា ដោយសារតែដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីអាចស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតចេញដីកា ឬបំពេញកិច្ចស៊ើបសួរណាមួយ ដែលខ្លួនយល់ឃើញថាមានប្រយោជន៍ដល់ការស៊ើបសួរ វិសាលភាពនៃការស៊ើបអង្កេតត្រូវបានកំណត់ដោយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។ អង្គបុរេជំនុំជម្រះយល់ឃើញថា លក្ខខណ្ឌដូចមានចែងនៅក្នុងវិធាន ៥៥(៣) ដែលដាក់កំណត់លើ ស.ច.ស អនុវត្តដូចគ្នាទៅនឹងដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីអាចជម្រាបជូន ស.ច.ស ឬសហព្រះរាជអាជ្ញា អំពីអង្គហេតុថ្មី ប៉ុន្តែខ្លួនមិនមានសិទ្ធិស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរលើអង្គហេតុទាំងនេះឡើយ ដរាបណាសហព្រះរាជអាជ្ញាមិនបានបញ្ចូលអង្គហេតុទាំងនេះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទេនោះ។

១២. នៅក្នុងករណីនេះ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ទោះបីជាសហព្រះរាជអាជ្ញាបានកម្រិតវិសាលភាពនៃការស៊ើបសួរដែលមានការស្នើសុំពង្រីកដល់ការរៀបការដោយបង្ខំ និងទំនាក់ទំនងផ្លូវភេទដោយបង្ខំ លើតែអំពើដែលបានប្រព្រឹត្តឡើងនៅក្នុងខេត្តកំពត និងខេត្តតាកែវ ដូចដែលដើមបណ្តឹងមួយចំនួនបានចោទប្រកាន់នៅក្នុងកថាខណ្ឌទី២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីពីរ[៤២] ក៏ដោយ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីបីដែលបានចេញមុនពេលដីកាសម្រេចដែលត្រូវបានជំទាស់បានធ្វើឡើង សហព្រះរាជអាជ្ញាបានអនុញ្ញាតឱ្យ

[៤២] សហព្រះរាជអាជ្ញាបានអនុញ្ញាតឱ្យ ស.ច.ស បើកការស៊ើបសួរលើអង្គហេតុដទៃៗទៀតណាមួយ ប្រសិនបើអង្គហេតុទាំងនោះជួយកំណត់បានពី (ក) ធាតុផ្សំខាងយុត្តាធិការ ចាំបាច់ដើម្បីបញ្ជាក់បានថាតើបញ្ហាខាងអង្គហេតុ ដូចដែលបានយោងនៅក្នុងកថាខណ្ឌទីពីរនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីពីរ ជាបទឧក្រិដ្ឋក្នុងយុត្តាធិការរបស់ អ.វ.ត.ក ដែរឬអត់ ឬ (ខ) ទម្រង់នៃការទទួលខុសត្រូវរបស់ នួន ជា អៀង សារី ខៀវ សំផន ឬ អៀង ធីរិទ្ធ ទាក់ទិននឹងបញ្ហាទាំងនេះ (ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទី២ កថាខណ្ឌ ៦)។



PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE

ស.ច.ស ពិចារណា និងស៊ើបអង្កេតបន្ថែមលើហេតុការណ៍ដែលបានចោទប្រកាន់អំពីការរៀបការដោយបង្ខំ និងទំនាក់ទំនងផ្លូវភេទដោយបង្ខំ ក្រៅពីការចោទប្រកាន់អំពីការរៀបការដោយបង្ខំ និងទំនាក់ទំនងផ្លូវភេទដោយបង្ខំដូចបានលើកឡើងនៅក្នុងកថាខណ្ឌខាងលើ *ប្រសិនបើ ស.ច.ស ពិចារណាថាសមស្រប*។

១៣. អង្គបុរេជំនុំជម្រះយល់ឃើញថា សំណើលើកទីមួយ សំណើលើកទីពីរ និងសំណើលើកទីបី បានបំពេញលក្ខណៈសម្បត្តិជាសំណើសុំបំពេញកិច្ចស៊ើបសួរ អនុលោមតាមវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង ហើយដីកាសម្រេចដែលត្រូវបានជំទាស់នោះ ជាដីកាសម្រេចបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរ។ ហេតុដូច្នេះ បណ្តឹងឧទ្ធរណ៍នេះអាចទទួលយកបាន អនុលោមតាមវិធាន ៧៤(៤)(ក) នៃវិធានផ្ទៃក្នុង។

## IV. អង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍

១៤. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញមានចំណុចដូចខាងក្រោម ដែលបានលើកឡើងដោយ ស.ច.ស នៅពេល ស.ច.ស បានពិចារណាលើសំណើសុំបំពេញកិច្ចស៊ើបសួរ៖

១. ស.ច.ស មានឆន្ទានុសិទ្ធិទូលំទូលាយ។

២. ដោយសារមិនមានលក្ខខណ្ឌច្បាស់លាស់ណាមួយនៅក្នុងវិធានផ្ទៃក្នុង ស.ច.ស មានឆន្ទានុសិទ្ធិសម្រេចលើភាពចាំបាច់ ឬកាលានុវត្តភាពក្នុងការសម្រេចបានកិច្ចស៊ើបសួរ ទោះជាកិច្ចស៊ើបសួរនោះត្រូវស្នើឡើងដោយភាគីណាមួយក្តី[៤៣]។

៣. ប្រសិនបើកិច្ចស៊ើបសួរត្រូវបានបដិសេធចោលនៅក្នុងដំណាក់កាលស៊ើបសួរ អង្គជំនុំជម្រះសាលាដំបូងនៅតែអាចសម្រេចបង្គាប់ឱ្យបំពេញកិច្ចស៊ើបសួរបាន នៅពេលក្រោយ[៤៤]។

៤. ខុសពីក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា(“ក.ន.ព.ក”) វិធានផ្ទៃក្នុងមិនផ្តល់អំណាចឱ្យអង្គបុរេជំនុំជម្រះបង្គាប់ឱ្យបំពេញកិច្ចស៊ើបសួរបន្ថែមឡើយ ប៉ុន្តែវិធានផ្ទៃក្នុងកំណត់តួនាទីឱ្យអង្គបុរេជំនុំជម្រះត្រឹមតែសម្រេចលើបណ្តឹងឧទ្ធរណ៍តែប៉ុណ្ណោះ[៤៥]។

---

[៤៣] សាលដីកាសាធារណៈលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ D164/4/13 (“សាលដីកាទាក់ទងនឹងឃ្លាំងផ្ទុកឯកសាររួម”) កថាខណ្ឌ ២២។

[៤៤] សាលដីកាទាក់ទងនឹងឃ្លាំងផ្ទុកឯកសាររួម កថាខណ្ឌ ២២ និង ជើងទំព័រ ៣៥ យោងទៅលើវិធាន ៩៣ នៃវិធានផ្ទៃក្នុង។

៥. ដោយសារតែសេចក្តីសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ ជាប់ពាក់ព័ន្ធនឹងអង្គហេតុ ស.ច.ស ជាចៅក្រមស្ថិតក្នុងស្ថានភាពល្អបំផុតក្នុងការវាយតម្លៃសំណើនោះ ដោយសារខ្លួនយល់ដឹងអំពីសំណុំរឿង។ វាជាការមិនសមស្របប្រសិនបើអង្គបុរេជំនុំជម្រះយកការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនទៅជំនួសការអនុវត្តឆន្ទានុសិទ្ធិរបស់ ស.ច.ស នោះ[៤៦]។

១៥. ដោយពិចារណាលើប្រវត្តិនៃអង្គហេតុនេះ និងក្រោយពីបានស្វែងរកបទដ្ឋានណែនាំនៅក្នុងយុត្តិសាស្ត្ររបស់សាលាក្តីអន្តរជាតិនានា អង្គបុរេជំនុំជម្រះបានបង្ហាញយ៉ាងច្បាស់លាស់អំពីបទដ្ឋាននៃការពិនិត្យឡើងវិញលើបណ្តឹងឧទ្ធរណ៍ ដែលពាក់ព័ន្ធនឹងសេចក្តីសម្រេចដែលបានធ្វើឡើងតាមឆន្ទានុសិទ្ធិ[៤៧]។ អង្គបុរេជំនុំជម្រះបានបង្ហាញថា សេចក្តីសម្រេចបែបនេះអាចត្រូវបានច្រានចោលប្រសិនបើដើមបណ្តឹងឧទ្ធរណ៍បង្ហាញថា សេចក្តីសម្រេចដែលខ្លួនតវ៉ានោះ៖

១. ផ្អែកលើការបកស្រាយមិនត្រឹមត្រូវលើច្បាប់ជាធរមាន។

២. ផ្អែកលើការសន្និដ្ឋានមិនត្រឹមត្រូវលើអង្គហេតយ៉ាងច្បាស់ក្រឡែត។ ឬ

៣. មានភាពអយុត្តិធម៌ ឬមិនសមហេតុផល ដែលបង្កើតជាការរំលោភបំពានលើឆន្ទានុសិទ្ធិរបស់ ស.ច.ស[៤៨]។

១៦. មូលដ្ឋានទាំងបីនេះគឺជាមូលដ្ឋានតែមួយគត់ដែលអង្គបុរេជំនុំជម្រះអាចបញ្ជូនសេចក្តីសម្រេចមួយនេះឱ្យទៅស.ច.ស ពិចារណាឡើងវិញ។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា មិនមែនគ្រប់កំហុសអង្គច្បាប់ ឬកំហុសអង្គហេតុទាំងអស់អាចនឹងធ្វើឱ្យការអនុវត្តឆន្ទានុសិទ្ធិគ្មានសុពលភាពដែលជាហេតុនាំឱ្យច្រានចោលដីកាសម្រេចឡើយ។ ដើមបណ្តឹងឧទ្ធរណ៍មានបន្ទុកក្នុងការបង្ហាញថា កំហុសអង្គច្បាប់ ឬកំហុសអង្គហេតុ ពិតជា នាំឱ្យសេចក្តីសម្រេចនោះគ្មានសុពលភាព ឬនាំឱ្យមានភាពអយុត្តិធម៌។

១៧. អង្គបុរេជំនុំជម្រះសូមពិនិត្យមើលមូលដ្ឋានទីមួយនៃបណ្តឹងឧទ្ធរណ៍។

---

[៤៥] សាលដីកាទាក់ទងនឹងឃ្លាំងផ្ទុកឯកសាររួម កថាខណ្ឌ ២៥។

[៤៦] *ដូចដើងទំព័រខាងលើ។*

[៤៧] សាលដីកាទាក់ទងនឹងឃ្លាំងផ្ទុកឯកសាររួម។ សាលដីកានេះបានយកតាមលក្ខខណ្ឌសាកល្បងដែលអង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការ ICTY បានបង្កើតឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍បន្ទាន់បន្ទុំ លើរឿងក្តី Slobodan Milošević ទល់នឹងរដ្ឋអាជ្ញា IT-02-54-AR73.7 ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០០៤។

[៤៨] សាលដីកាទាក់ទងនឹងឃ្លាំងផ្ទុកឯកសាររួម កថាខណ្ឌ ២៥-២៧។

00568530



## ក. មូលដ្ឋានទីមួយនៃបណ្តឹងឧទ្ធរណ៍៖ ការសម្រេចបដិសេធដោយមានកំហុស លើសំណើសុំ ដោយហេតុថាបុគ្គលទាំងឡាយដែលបានស្នើសុំ ឱ្យសាកសួរនោះ ត្រូវបានសាកសួររួចទៅហើយ

១៨. ដើមបណ្តឹងឧទ្ធរណ៍សន្និដ្ឋានថា ដីកាសម្រេចដែលត្រូវបានជំទាស់ផ្អែកលើការបកស្រាយមិនត្រឹមត្រូវលើច្បាប់ជាធរមាន នៅពេល ស.ច.ស សម្រេចបដិសេធសំណើសុំឱ្យសាកសួរសាក្សីមួយរូបអំពីការបាត់ខ្លួនដោយបង្ខំ[៤៩] និងសាកសួរសាក្សីចំនួន [redacted] នាក់ទៀត អំពីការរៀបការដោយបង្ខំ និងអំពើហិង្សាខាងផ្លូវភេទ[៥០]ដោយឈរលើមូលដ្ឋានថា សាក្សីទាំងនេះត្រូវបានសាកសួររួចហើយ[៥១]។ ដើមបណ្តឹងឧទ្ធរណ៍ផ្តល់ទឡ្ហីករណ៍ថា ដោយសារ ស.ច.ស មានកាតព្វកិច្ចស៊ើបអង្កេតលើអង្គហេតុដូចបានដាក់ជូននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យ ស៊ើបសួរបន្ថែម[៥២] ហើយនឹងកាតព្វកិច្ចដាក់បញ្ចូលនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនូវ

---

[៤៩] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១២ និងជើងទំព័រ ៩ ដោយបានចង្អុលយោងដោយភ័ន្តច្រឡំលើសាក្សី [redacted] ខណៈសំណើលើកទីមួយ និងដីកាសម្រេចដែលត្រូវបានជំទាស់បានលើកយោងសាក្សី [redacted]។ សូមមើលសំណើលើកទីមួយ លេខយោងជើងទំព័រ ៦៩ ដែលចង្អុលយោងលើការសម្ភាសន៍របស់ DC-Cam លើរូបគាត់ ERN (English) 00324282។ ឯកសារសម្ភាសន៍នេះ "លើកឡើងថា គាត់បានចូលរួមចាប់ខ្លួនវៀតណាមនៅក្នុងឆ្នាំ១៩៧៨"។ ដើមបណ្តឹងគូសបញ្ជាក់បន្ថែមទៀតថា ដីកាសម្រេចដែលត្រូវបានជំទាស់បង្ហាញថា [redacted] បានចូលខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៅក្នុងរឿងក្តីលេខ 00១ ដូច្នេះ ការសាកសួរបន្ថែមមិនចាំបាច់ធ្វើឡើងឡើយ (បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១២)។

[៥០] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១២ និងជើងទំព័រ ៩ យោងទៅលើ [redacted] (សំណើលើកទីពីរ) និង [redacted] (សំណើលើកទីបី)។

[៥១] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១២-២៩។

[៥២] មាត្រា ១២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា និងវិធាន ៥៥ [illegible]

00568531



អង្គហេតុសំខាន់ៗដើម្បីជាមូលដ្ឋាននៃការកំណត់បទចោទចំពោះបទល្មើសដែលបានចោទប្រកាន់[៥៣] ការសម្រេចបដិសេធអាចមានយុត្តិកម្មតែក្នុងករណីដែលការសាកសួរដែលបានធ្វើហើយនោះបានបង្កើតអង្គហេតុសំខាន់ៗ[៥៤]។ ដើម្បីជាមូលដ្ឋាននៃទឡ្ហីករណ៍នេះ ដើមបណ្តឹងឧទ្ធរណ៍លើកឡើងថា សាក្សីទាំងនោះត្រូវបានសាកសួរ នៅមុនពេលចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទីពីរ ហើយមិនត្រូវបានសាកសួរសំនួរជាក់លាក់ដែលពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងបទឧក្រិដ្ឋពាក់ព័ន្ធនឹងផ្លូវភេទឡើយ ឬនៅពេលសាកសួរនោះ ការសាកសួរមិនបានធ្វើឡើងឱ្យបានគ្រប់គ្រាន់ដើម្បីបង្កើតបាននូវធាតុផ្សំនៃបទឧក្រិដ្ឋដែលពាក់ព័ន្ធឡើយ។

១៩. ពាក់ព័ន្ធនឹងការបាត់ខ្លួនដោយបង្ខំវិញ ដើមបណ្តឹងឧទ្ធរណ៍ចង្អុលយោងលើការសាកសួរសាក្សី [redacted] ដែលការសាកសួរនោះបានធ្វើឡើងសម្រាប់ការជំនុំជម្រះលើរឿងក្តីលេខ ០០១។ ដើមបណ្តឹងឧទ្ធរណ៍អះអាងថា ស.ច.ស បានសម្រេចបដិសេធដោយមានកំហុស លើសំណើរបស់ខ្លួនដែលបានស្នើសុំបំពេញកិច្ចស៊ើបសួរ ពីព្រោះ ស.ច.ស មានកាតព្វកិច្ចស៊ើបអង្កេត និងកំណត់អត្តសញ្ញាណអង្គហេតុនានាដែលត្រូវបញ្ចូលទៅក្នុងបទឧក្រិដ្ឋជាក់លាក់ ដែលជាការបាត់ខ្លួនដោយបង្ខំ[៥៥]។ ចំពោះការរៀបការដោយបង្ខំ និងបទឧក្រិដ្ឋពាក់ព័ន្ធនឹងផ្លូវភេទ ដើមបណ្តឹងឧទ្ធរណ៍បានពិនិត្យមើលឡើងវិញនូវការស្តាប់ចម្លើយពីមុនៗលើសាក្សី [redacted] ដែលខ្លួនបានដាក់សំណើសុំឱ្យសាកសួរម្តងទៀតអំពីការចោទប្រកាន់លើហេតុការណ៍នៃការរៀបការ ដោយបង្ខំនៅខេត្តស្វាយរៀង និងខេត្តកំពង់ចាម[៥៦]។ ដើមបណ្តឹងឧទ្ធរណ៍អះអាងថា សាក្សីជាច្រើនបានលើកឡើងនូវឧទាហរណ៍នៃបទឧក្រិដ្ឋពាក់ព័ន្ធនឹងផ្លូវភេទ ចេញមកដោយឯកឯង ប៉ុន្តែសាក្សីទាំងនេះមិន ដែលត្រូវបានសាកសួរអំពីស្ថានភាព និងព័ត៌មានពិស្តារនៃបទល្មើសទាំងនេះឡើយ។ ហេតុនេះហើយ សក្ខីកម្មរបស់សាក្សីទាំងនេះគ្រាន់តែជាចំណែកមួយនៃហេតុការណ៍ដែលបានកើតឡើងប៉ុណ្ណោះ[៥៧]។

---

[៥៣] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១៣។

[៥៤] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១៤។

[៥៥] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៩។

[៥៦] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១៨-២៥។

[៥៧] សំណើលើកទីបី កថាខណ្ឌ ៣។

00568532



២០. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ដើមបណ្តឹងឧទ្ធរណ៍តម្រូវឱ្យបង្ហាញថា ភស្តុតាងរបស់សាក្សីទាំងមូលនោះ មិនបានផ្តល់ជាព័ត៌មានគ្រប់គ្រាន់ដើម្បីចង្អុលបង្ហាញឱ្យបានពេញលេញនូវធាតុផ្សំនៃការបាត់ខ្លួនដោយបង្ខំ ការរៀបការដោយបង្ខំ និងបទឧក្រិដ្ឋពាក់ព័ន្ធនឹងផ្លូវភេទឡើយ។ លុះត្រាតែមានការបង្ហាញដូចនោះ ទើបដើមបណ្តឹងឧទ្ធរណ៍អាចបង្ហាញថា មិនមានភស្តុតាងគ្រប់គ្រាន់អំពីបទឧក្រិដ្ឋ ដែលនឹងត្រូវដាក់បញ្ចូលនៅក្នុងដីកាដំណោះស្រាយ។ អង្គបុរេជំនុំជម្រះក៏កត់សម្គាល់ឃើញទៀតថា ដើម្បីឱ្យបទឧក្រិដ្ឋទាំងនេះអាចបង្កើតជាមូលដ្ឋាននៃការចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបាននោះ ភស្តុតាងត្រូវបង្ហាញថា បទឧក្រិដ្ឋទាំងនេះបានបង្កើតជាផ្នែកមួយនៃការវាយប្រហារដែលមានលក្ខណៈទូលំទូលាយ និងជាប្រព័ន្ធ ដែលជនត្រូវចោទបានប្រព្រឹត្តទៅលើប្រជាជនស៊ីវិល។

<u>(i) ការបាត់ខ្លួនដោយបង្ខំ</u>

*១. សាក្សី* [redacted]

២១. ជាបឋម អង្គបុរេជំនុំជម្រះពិចារណាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងការបដិសេធរបស់ ស.ច.ស មិនស្តាប់ចម្លើយសាក្សី លោក [redacted] ជាថ្មីម្តងទៀត ដើម្បីទទួលបាននូវភស្តុតាងជាក់លាក់អំពីបទឧក្រិដ្ឋនៃការបាត់ខ្លួនដោយបង្ខំ។

២២. នៅក្នុងសំណើទីមួយរបស់ខ្លួន សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបរិយាយអំពីភាពធ្ងន់ធ្ងរនៃបទល្មើសនៃការបាត់ខ្លួនដោយបង្ខំ[៥៨] ហើយអះអាងថា តាមគោលការណ៍ច្បាប់អន្តរជាតិ ការប្រព្រឹត្តបទឧក្រិដ្ឋនៃការបាត់ខ្លួនដោយបង្ខំដែលមានលក្ខណៈទូលំទូលាយនិងជាប្រព័ន្ធនឹងបង្កើតឱ្យមានឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[៥៩]។ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី អះអាងថា តុលាការមានកាតព្វកិច្ចក្នុងការស៊ើបអង្កេតលើឧក្រិដ្ឋកម្មបែបនេះ[៦០] ហើយថា ឧក្រិដ្ឋកម្មបែបនេះស្ថិតនៅក្រោមយុត្តាធិការរបស់អ.វ.ត.ក[៦១]។ សំណើទីមួយរៀបរាប់យ៉ាងសង្ខេបថា នៅក្នុងសំណុំ

---

[៥៨] សំណើលើកទីមួយ កថាខណ្ឌ ២-៤។

[៥៩] សំណើលើកទីមួយ កថាខណ្ឌ ៥។

[៦០] សំណើលើកទីមួយ កថាខណ្ឌ ៦-៧។

[៦១] សំណើលើកទីមួយ កថាខណ្ឌ ១០-១៤, ១៩-២២។

រឿងបច្ចុប្បន្ន មានភស្តុតាងបញ្ជាក់ពីការប្រព្រឹត្តបទឧក្រិដ្ឋនៃការបាត់ខ្លួនដោយបង្ខំ ដែលមានលក្ខណៈទូលំទូលាយនិងជាប្រព័ន្ធ ក្នុងរបបខ្មែរក្រហម[៦២]។ នៅក្នុងបណ្តឹងឧទ្ធរណ៍របស់ខ្លួន ដើម-បណ្តឹងឧទ្ធរណ៍អះអាងថា លោក [redacted] មិនបានផ្តល់សក្ខីកម្មនៅក្នុងអំឡុងពេលជំនុំជម្រះនោះទេ ហើយគាត់ត្រូវបានដកចេញពីបញ្ជីសាក្សី។ ដើមបណ្តឹងឧទ្ធរណ៍លើកទឡ្ហីករណ៍ថា នៅក្នុងបទសម្ភាសន៍លើកមុន គាត់មិនត្រូវបានសួរលម្អិតពីការបាត់ខ្លួនដោយបង្ខំ និង "ភាពជាក់លាក់នៃការបាត់ខ្លួន" ឡើយ[៦៣]។ ហេតុដូច្នេះ ដើមបណ្តឹងឧទ្ធរណ៍សន្និដ្ឋានថា ស.ច.ស មិនបានបំពេញនូវសមត្ថកិច្ចរបស់ខ្លួនក្នុងការស៊ើបអង្កេត និងកំណត់អត្តសញ្ញាណនៃអង្គហេតុ ដែលត្រូវបញ្ជាក់ពីការបាត់ខ្លួនដោយបង្ខំនោះទេ។

២៣. អង្គបុរេជំនុំជម្រះលើកឡើងសារជាថ្មីថា ដើមបណ្តឹងឧទ្ធរណ៍មានបន្ទុកក្នុងការបង្ហាញថា តើការស្តាប់ចម្លើយសាក្សីសារជាថ្មីដែលស្នើឡើងនេះ អាចជួយបង្ហាញពីធាតុផ្សំបទឧក្រិដ្ឋដោយរបៀបណា ដើម្បីឱ្យការស្តាប់ចម្លើយនេះ អាចត្រូវបានបញ្ចូលនៅក្នុងដីកាដំណោះស្រាយ។ ដោយយោងលើការអះអាងរបស់ដើមបណ្តឹងឧទ្ធរណ៍ ដែលថា បទឧក្រិដ្ឋនេះ ស្ថិតនៅក្នុងព្រំដែននៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[៦៤] វាមានភាពចាំបាច់ដើម្បីបង្ហាញថា បទឧក្រិដ្ឋនេះបង្កើតបានជាផ្នែកមួយនៃការវាយប្រហារ ដែលមានលក្ខណៈទូទៅ និងជាប្រព័ន្ធប្រឆាំងទៅនឹងប្រជាជនស៊ីវិល[៦៥]។ សំណើទីមួយ និងបណ្តឹងឧទ្ធរណ៍ មិនបានបង្ហាញពីសម្ភារៈសំខាន់ ដែលមាននៅក្នុងភស្តុតាងពីពេលមុនរបស់លោក [redacted] ដែលអាចបង្ហាញថា គាត់មានព័ត៌មានបន្ថែមទៀតដើម្បីជួយដល់កិច្ចស៊ើបអង្កេតលើបទឧក្រិដ្ឋនៃការបាត់ខ្លួនដោយបង្ខំនោះទេ។ ដោយគ្មានការវិភាគថាតើភស្តុតាងរបស់គាត់អាចមានអ្វីខ្លះនោះ ឬ ថាតើមានព័ត៌មានបន្ថែមអ្វីខ្លះដែលដើមបណ្តឹងឧទ្ធរណ៍ចង់បានពីសាក្សីនេះ គេមិនអាចអះអាងថា ស.ច.ស មានកំហុសក្នុងការបដិសេធ

---

[៦២] សំណើលើកទីមួយ កថាខណ្ឌ ២៣-២៥។

[៦៣] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៩។

[៦៤] សំណើលើកទីមួយ កថាខណ្ឌ ៥។

[៦៥] មិនចាំបាច់ថាអំពើនោះត្រូវបានប្រព្រឹត្តឡើងក្នុងលក្ខណៈទូលំទូលាយ និងមានលក្ខណៈជាប្រព័ន្ធ ដូចលើកឡើងនៅក្នុងសំណើទីមួយ កថាខណ្ឌទី ៧ នោះទេ។ ការបែងចែកលក្ខណៈច្បាប់នេះត្រូវបានដោះស្រាយដោយអង្គបុរេជំនុំជម្រះត្រង់ចំណុចមូលដ្ឋានទីប្រាំនៃបណ្តឹងឧទ្ធរណ៍។

មិនស្តាប់ចម្លើយសាក្សីនេះសារជាថ្មីម្តងទៀតឡើយ។ អង្គបុរេជំនុំជម្រះមិនគាំទ្រដើមបណ្តឹងឧទ្ធរណ៍ ដោយផ្អែកលើមូលដ្ឋាននេះឡើយ។

(ii) ការរៀបការដោយបង្ខំ និងបទឧក្រិដ្ឋផ្លូវភេទផ្សេងៗទៀត

២៤. សំណើទីបីលើកឡើងអំពីការរៀបការដោយបង្ខំ និងបទឧក្រិដ្ឋផ្លូវភេទផ្សេងៗទៀត។ សំណើនេះស្នើឡើងថា បទសម្ភាសន៍ទាំងនេះគួរផ្តោតទៅលើការរៀបចំការរៀបអាពាហ៍ពិពាហ៍ទាំងនេះ ព្រមទាំងបញ្ជានានា ដែលបានដាក់មកតាមរយៈរចនាសម្ព័ន្ធរបស់ខ្មែរក្រហម ពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ ការដាក់ទោសចំពោះការប្រកែកមិនធ្វើតាមការបញ្ជាទាំងនេះ ព្រមទាំងការចេញបញ្ជាដោយផ្ទាល់ និងដោយបង្ខំរបស់ខ្មែរក្រហម ឲ្យប្តីប្រពន្ធរួមរក្សគ្នា ក្រោយពីបានរៀបអាពាហ៍ពិពាហ៍រួចហើយ។[៦៦]។ ទាក់ទងនឹងបទឧក្រិដ្ឋផ្លូវភេទផ្សេងទៀត សំណើទីបីលើកឡើងថា កិច្ចស៊ើបសួរគួរតែស្វែងរកឲ្យឃើញនូវអ្វីដែលត្រូវបានចាត់ទុកថា “ខុសសីលធម៌” ដើម្បីកំណត់ថាតើការប្រព្រឹត្តនេះជាមូលហេតុបង្កឲ្យមានបទឧក្រិដ្ឋទាក់ទងនឹងផ្លូវភេទនានាដែរឬយ៉ាងណា។ សំណើនេះក៏ស្នើឱ្យ ស.ច.ស ពិនិត្យលើព័ត៌មានលម្អិត និងកម្រិតនៃការកើតមាន និងពិនិត្យ ថាតើការអនុវត្តនានា ដូចជាការត្រួតពិនិត្យព្រហ្មចារីរបស់ស្ត្រី ដូចរៀបរាប់ឡើងដោយសាក្សីម្នាក់ផ្សេងទៀត ត្រូវបានអនុវត្តជាទូទៅនៅក្នុងរបបខ្មែរក្រហមដែរឬទេ[៦៧]។

២៥. ដីកាសម្រេចដែលត្រូវបានជំទាស់លើកឡើងថា បុគ្គលភាគច្រើនដូចបានរៀបរាប់នៅក្នុងសំណើទីបីនោះ ត្រូវបានស្តាប់ចម្លើយដោយការិយាល័យសហចៅក្រមស៊ើបអង្កេត (“ក.ស.ច.ស”) រួចហើយ “ដែលពាក់ព័ន្ធទៅនឹងការរៀបការដោយបង្ខំ ដូច្នេះ មិនមានការចាំបាច់សម្រាប់ការសម្ភាសន៍បន្ថែមលើបុគ្គលទាំងអស់នោះទេ”[៦៨]។ ទាក់ទងទៅនឹងបុគ្គលភាគច្រើន ដែលត្រូវ

---

[៦៦] សំណើទីបី កថាខណ្ឌ ៤។

[៦៧] សំណើទីបី កថាខណ្ឌ ៦។

[៦៨] ដីកាដែលត្រូវបានជំទាស់ កថាខណ្ឌ ១៤។ សូមមើលផងដែរ ដីកាដែលត្រូវបានជំទាស់ កថាខណ្ឌ ១៥ ទាក់ទងនឹងបុគ្គលដែលមានរាយឈ្មោះចំនួន [redacted] ដែល ស.ច.ស មិនអាចរកបាននូវព័ត៌មានលម្អិតគ្រប់គ្រាន់ ដើម្បីជួយដល់ការកំណត់អត្តសញ្ញាណ ទីកន្លែង និងការវាយតម្លៃបឋមនៃភស្តុតាងសំខាន់បាន។ បន្ថែមលើនេះ ដីកាសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ១៦ ទាក់ទងនឹងបុគ្គលដែលមានរាយឈ្មោះចំនួន [redacted] ដែលស្ថិតនៅក្នុងដំណាក់កាលត្រូវ



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

បានស្នើឱ្យសម្ភាសន៍លើបទឧក្រិដ្ឋផ្លូវភេទនោះ ដីកាសម្រេចដែលត្រូវបានជំទាស់អះអាងថា បុគ្គលទាំងនេះត្រូវបានសម្ភាសន៍ដោយ ក.ស.ច.ស រួចហើយ ដូច្នេះ មិនមានការចាំបាច់សម្រាប់ការសម្ភាសន៍បន្ថែមលើបុគ្គលទាំងអស់នោះទេ[៦៩]។

ខ. *សាក្សី* [redacted]

២៦. ដើមបណ្តឹងឧទ្ធរណ៍យោងទៅលើបទសម្ភាសន៍របស់លោក [redacted] កាលពីថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៨ និងចម្លើយរបស់គាត់ដែលអះអាងថា គាត់រៀបការនៅក្នុងឆ្នាំ១៩៧៨ ជាមួយអ្នកផ្សេងទៀតចំនួនប្រាំគូ[៧០]។ ដើមបណ្តឹងឧទ្ធរណ៍លើកទឡ្ហីករណ៍ថា ចម្លើយនេះមិនគ្រប់គ្រាន់ដើម្បីបង្កើតឱ្យបាននូវបទឧក្រិដ្ឋណាមួយឡើយ និងជាពិសេសធាតុផ្សំនៃបទឧក្រិដ្ឋរំលោភសេពសន្ថវៈ (ការប៉ុនប៉ង)ឱ្យមានផ្ទៃពោះដោយបង្ខំ ការដាក់ជាទាសករ(ផ្លូវភេទ) និងការរៀបការដោយបង្ខំ។ ដើមបណ្តឹងឧទ្ធរណ៍អះអាងថា គ្មានសំណួរណាមួយ ត្រូវបានចោទសួរទាក់ទងនឹងស្ថានភាពដែលត្រូវគេបង្ខំ គ្មានការព្រមព្រៀង ការរួមសង្វាសដែលអាចកើតឡើងតាមបញ្ជា ការសង្កេតពីទំនាក់ទំនងផ្លូវភេទក្រោយអាពាហ៍ពិពាហ៍ ប្រសិនបើមានកូនក្រោយការរៀបអាពាហ៍ពិពាហ៍ តើនរណាជាអ្នកចេញបញ្ជាឱ្យមានការរៀបអាពាហ៍ពិពាហ៍ (ដែលបង្កើតបានជាសង្វាក់នៃការបញ្ជាក្នុងតំបន់នេះ) ព្រមទាំងការឈឺចាប់ជាក់លាក់របស់ជនរងគ្រោះឡើយ[៧១]។

២៧. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា លោក [redacted] មិនមែនជាបុគ្គល [redacted] ក្នុងចំណោមបុគ្គលទាំងអស់ដែលត្រូវបានរៀបរាប់នៅក្នុងកថាខណ្ឌ ១៥ និង ១៦ នៃដីកាសម្រេចដែលត្រូវបានជំទាស់ទេ។ ហេតុដូច្នេះ ការរកឃើញពាក់ព័ន្ធទៅនឹងស្ថានភាពរបស់គាត់ នៅក្នុងដីកាសម្រេចនោះ គឺនៅត្រង់កថាខណ្ឌ១៤ ដែលអះអាងយ៉ាងសាមញ្ញថា "បុគ្គលភាគច្រើនត្រូវបានសម្ភាសន៍

---

ពិចារណាថាជាដើមបណ្តឹងរដ្ឋប្បវេណី ដែល ស.ច.ស បានរកឃើញថា បើទោះជាពួកគាត់ចោទប្រកាន់ថាមានការរៀបការដោយបង្ខំ ហើយដូច្នេះស្ថិតនៅក្នុងវិសាលភាពកំណត់នៃកិច្ចស៊ើបសួរក៏ដោយ "*ក៏គ្មានមូលដ្ឋានគ្រប់គ្រាន់ដើម្បីសន្និដ្ឋានថា ភស្តុតាងរបស់ពួកគាត់នឹងជួយដល់ភស្តុតាងដែលទទួលបានទៅដំណាក់កាលស៊ើបសួរនោះដែរ*"។

[៦៩] ដីកាដែលត្រូវបានជំទាស់ កថាខណ្ឌ ១៧។

[៧០] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១៨ ដោយយោងទៅលើឯកសារ D125/16 នៅត្រង់ទំព័រ ៥។

[៧១] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១៩។



PRE-TRIAL CHAMBER · E.C.C.C · C.E.T.C · CHAMBRE PRÉLIMINAIRE

ដោយចៅក្រមរបស់ ក.ស.ច.ស រួចហើយ ទាក់ទងនឹងបញ្ហារៀបការដោយបង្ខំ ដូច្នេះ មិនមានការចាំបាច់សម្រាប់ការសម្ភាសន៍បន្ថែមលើបុគ្គលទាំងអស់នោះទេ”[៧២]។ បើទោះជាដីកាសម្រេចដែលត្រូវបានជំទាស់មិនមានសំអាងហេតុពេញលេញទាក់ទងនឹងបញ្ហានេះក៏ដោយ ក៏ចំណុចនេះមិនជាការសំខាន់ដែរ។ អង្គបុរេជំនុំជម្រះយល់ឃើញថា សាក្សីនេះមិនបានលើកឡើងពីបញ្ហារៀបការដោយបង្ខំទេ នៅក្នុងបទសម្ភាសន៍ដើមរបស់គាត់ ហើយគ្រាន់តែអះអាងថា ប្តីប្រពន្ធបួនគូផ្សេងទៀតបានរៀបការនៅពេលជាមួយគាត់ នៅក្នុងឆ្នាំ១៩៧៨។ អង្គបុរេជំនុំជម្រះយល់ឃើញថា ដើមបណ្តឹងឧទ្ធរណ៍មិនបានផ្តល់ឱ្យ ស.ច.ស នូវមូលដ្ឋានណាមួយ ដើម្បីជឿបានថា សាក្សីដែលស្នើឡើងនេះ ត្រូវបានបង្ខំឱ្យរៀបការ ឬមានព័ត៌មានពីបុគ្គលផ្សេងទៀត ដែលត្រូវបានបង្ខំឱ្យរៀបការ ដូចដែលបានចោទប្រកាន់ឡើងនៅក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទីពីរ ទីបី និងទីបួន នោះទេ។ មិនមានកំហុសអង្គហេតុ ឬកំហុសអង្គច្បាប់ ឬការរំលោភអំណាចឆន្ទានុសិទ្ធិណាមួយ ត្រូវបានបង្ហាញឱ្យឃើញឡើយ។

២៨. មានបុគ្គលចំនួន[redacted]ទៀត ដែលត្រូវបានស្នើសុំឱ្យស្តាប់ចម្លើយ ដូចរៀបរាប់នៅក្នុងសំណើទីពីរ និងទីបី ដែលអ្នកទាំងនោះមិនត្រូវបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍ទេ។ អង្គបុរេជំនុំជម្រះមិនបានពិចារណាលើបុគ្គលទាំងនេះ តាមមូលដ្ឋានទីមួយនៃបណ្តឹងឧទ្ធរណ៍ទេ ប៉ុន្តែអង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ខ្លួនបានពិនិត្យមើលចម្លើយសាក្សី និង/ឬ របាយការណ៍ពាក់ព័ន្ធដែលបានមកពីអង្គភាពជនរងគ្រោះ ទាក់ទងនឹងបុគ្គលនីមួយៗក្នុងចំណោមបុគ្គលទាំងនេះ ក្នុងគោលបំណងយល់ឱ្យបានច្បាស់ជាងនេះ ទៅលើព័ត៌មាន ដែល ស.ច.ស មាន នៅពេលខ្លួនធ្វើការពិចារណាទៅលើសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរទាំងនោះ។ ការពិនិត្យនេះបង្ហាញឱ្យឃើញថា សាក្សីជាច្រើនអះអាងថា ខ្លួនត្រូវបានបង្ខំឱ្យរៀបការជាមួយនឹងបុគ្គល ដែលខ្លួនមិនបានជ្រើសរើស[៧៣]។ បុគ្គលមួយចំនួនអះអាងយ៉ាងជាក់លាក់ថា ក្នុងករណីមិនយល់ព្រម គេប្រាប់ពួកគាត់ថា

[៧២] ដីកាដែលត្រូវបានជំទាស់ កថាខណ្ឌ ១៤។

[៧៣] សូមមើលឯកសារ D166/100 ទំព័រ ៣។ ឯកសារ D166/101 ទំព័រ ៥។ ឯកសារ D166/36 ទំព័រ ៤។ ឯកសារ D125/23 ទំព័រ ៥។ ឯកសារ D125/18 ទំព័រ ៧។ ឯកសារ D125/45 ទំព័រ ៦។ ឯកសារ D125/46 ទំព័រ ៦។ ឯកសារ D125/48 ទំព័រ ៣។ ឯកសារ D125/61 ទំព័រ ២។ ឯកសារ D125/117 ទំព័រ ២។ ឯកសារ D125/127 ទំព័រ ៣។ ឯកសារ D22/146 ទំព័រ ៤។ ឯកសារ D108/6/11 ទំព័រ ៣។



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C * C.E.T.C

នឹងមានលទ្ធផលអាក្រក់កើតឡើងចំពោះពួកគាត់[៧៤]។ សាក្សីមួយចំនួនតូចទៀត បានពណ៌នាពីអ្វីដែលពួកគាត់ត្រូវបានតម្រូវឱ្យធ្វើ ដើម្បីសុំការអនុញ្ញាតពីប្រធានកង ប្រសិនបើពួកគាត់ប្រាថ្នាចង់រៀបការ ហើយការរៀបការនឹងត្រូវបានគេរៀបចំឱ្យ[៧៥]។ សាក្សីពីរនាក់បានរៀបរាប់ពីអត្ថិភាពនៃប្រព័ន្ធរៀបការទាំងពីរ[៧៦]។ សាក្សី [redacted] ដែលខុសពីសាក្សីសំខាន់ផ្សេងៗទៀតដែលត្រូវបានស្នើសុំស្ដាប់ចម្លើយសារជាថ្មី ប៉ុន្តែ មិនត្រូវបានរៀបរាប់នៅក្នុងបណ្ដឹងឧទ្ធរណ៍នោះ មិនបានអះអាងថាការរៀបការរបស់គាត់ត្រូវបានរៀបចំទេ។ នៅក្នុងបរិបទនេះ ដើមបណ្ដឹងឧទ្ធរណ៍ខកខានក្នុងការបង្ហាញថា កំហុសនេះធ្វើឱ្យដីកាសម្រេចអស់សុពលភាព ក្នុងការបដិសេធសំណើសុំស្ដាប់ចម្លើយបុគ្គលជាក់លាក់នេះសារជាថ្មី ឬបង្ហាញថា កំហុសនេះនាំឱ្យមានភាពអយុត្តិធម៌។ ដូច្នេះ មូលដ្ឋានរងនៃបណ្ដឹងឧទ្ធរណ៍នេះ ត្រូវបានច្រានចោល។

---

៧៤ សម្រាប់ជាឧទាហរណ៍នៃលទ្ធផលធ្ងន់ធ្ងរបែបនេះ ដែលរៀបរាប់ដោយសាក្សីដែលត្រូវបានស្នើសុំឱ្យស្ដាប់ចម្លើយម្ដងទៀតនោះ សូមមើលឯកសារ D166/100 ទំព័រ ៣ ដែលបង្ហាញថា ពួកគាត់ត្រូវបានបង្ខំឱ្យទៅធ្វើការនៅទីឆ្ងាយដែលជាផ្នែកមួយនៃកងចល័ត។ ឯកសារ D166/36 ទំព័រ ៤ ដែលបង្ហាញថា ពួកគាត់នឹងត្រូវបានបញ្ជូនទៅកសាង។ ឯកសារ D125/46 ទំព័រ ៦ ដែលបង្ហាញថា ស្ត្រីម្នាក់នឹងត្រូវបានគេគំរាមឱ្យរៀបការជាមួយនឹងទាហានពិការម្នាក់ ប្រសិនបើគាត់ជំទាស់នឹងជម្រើសរបស់អង្គការ។ ឯកសារ D125/117 ទំព័រ ២ ដែលបង្ហាញថា នឹងមានលទ្ធផលប៉ះពាល់ ហើយគាត់បានដឹងពីករណីចាប់ខ្លួននិងសម្លាប់ស្ត្រីម្នាក់ដែលប្រកែកមិនព្រមរៀបការ។ ឯកសារ D108/6/11 ទំព័រ ៣ D22/146 ទំព័រ ៤ ដែលគាត់មានអាយុ ១៥ឆ្នាំ នៅពេលនោះ ហើយត្រូវបានគំរាមដោយប្រើកាំភ្លើង AK ពីឈ្លបប្រុសម្នាក់ ដែលប្រាប់គាត់ថា ប្រសិនបើគាត់មិនរៀបការជាមួយនឹងប្រធានកងឈ្លបភូមិទេ គេនឹងសម្លាប់គាត់។

៧៥ សូមមើលឯកសារ D166/65 ទំព័រ ៥។ ឯកសារ D125/25 ទំព័រ ៥ ដែលបង្ហាញថានៅក្នុងកងរបស់គាត់ គេអាចជ្រើសរើសអ្នកដែលគេចង់រៀបការជាមួយ ហើយបន្ទាប់ពីបានការអនុញ្ញាតរួចហើយ អង្គការនឹងរៀបចំការរៀបការនោះ។ ឯកសារ D166/94 ទំព័រ ៥ ដែលបង្ហាញថាគាត់បញ្ជាក់ពីចេតនារៀបការ ហើយប្រធានរបស់គាត់ទាក់ទងកងរបស់ស្ត្រីនោះ ដើម្បីរៀបចំការរៀបការ។ ឯកសារ D166/123 ទំព័រ ៧ ដែលបង្ហាញថាការរៀបការដោយគ្មានការអនុញ្ញាតិបែបនេះ នឹងត្រូវទទួលទណ្ឌកម្មដោយប្រហារជីវិត។

៧៦ ឯកសារ D125/169 ទំព័រ ៦ ដែលបង្ហាញថា ទម្រង់មួយនៃការរៀបការនោះគឺមានសំណើពីបុរសម្នាក់ទៅកាន់ប្រធានកងបុរស ដែលជាអ្នកស្នើទៅប្រធានកងនារី ហើយទម្រង់មួយទៀតនៃការរៀបការនោះគឺការរៀបការដែលរៀបចំដោយអង្គការដែលគ្មាននរណាអាចប្រកែកបានឡើយ នេះគឺជា "ការរៀបការដោយបង្ខំ"។ ឯកសារ D125/184 ទំព័រ ៦-៧ ដែលបង្ហាញថាការរៀបការជាក្រុមបន្តបន្ទាប់ត្រូវបានយល់ព្រមបន្ទាប់ពីមានការអនុញ្ញាតិពីអាជ្ញាធរ ប៉ុន្តែការរៀបការក្នុងជួរយោធា អាចធ្វើទៅបាននៅពេលណាមានបញ្ជាពីថ្នាក់លើតែប៉ុណ្ណោះ។

*៣. សាក្សី* [redacted]

២៩. ស្រដៀងគ្នាទៅនឹងករណីលោក [redacted] ដែរ ដើមបណ្ដឹងឧទ្ធរណ៍លើកឡើងថា អ្នកសម្ភាសន៍គួរបានសួរអំពីស្ថានភាពនៃការរៀបការដោយបង្ខំ ហើយពន្យល់ពីភាពខុសគ្នារវាងពាក្យ "រៀបចំ" ដែលប្រើនៅក្នុងសំណួរអំពីការរៀបការដោយបង្ខំ និងពាក្យ"ឆ្លើយតប" ដែលប្រើនៅក្នុងចម្លើយទៅកាន់សំណួរនោះ[៧៧]។ បើទោះជាអង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ប្រតិចារឹកជាភាសាអង់គ្លេសនិងភាសាបារាំង មានភាពខុសគ្នាលើចំណុចនេះក៏ដោយ ក៏ខ្លួនយល់ឃើញថាមិនមានភាពចាំបាច់ដើម្បីដោះស្រាយបញ្ហានេះបន្ថែមទៀត ដោយហេតុថា ដើមបណ្ដឹងឧទ្ធរណ៍មិនបានវិភាគភស្តុតាងដែលបានប្រមូលរួចហើយ និងពុំបានផ្ដល់ព័ត៌មានលម្អិត ថាតើភស្តុតាងនោះបង្កើតបាននូវធាតុផ្សំជាក់លាក់ នៃបទឧក្រិដ្ឋពាក់ព័ន្ធនានាសម្រាប់ដីកាដំណោះស្រាយដោយរបៀបណា ថាតើឧក្រិដ្ឋកម្មនោះគឺជាកម្មវត្ថុ នៃដីកាបញ្ជូនរឿងឱ្យទៅជំនុំជម្រះដែរឬទេ។ ដើម-បណ្ដឹងឧទ្ធរណ៍មិនបានបំពេញនូវលក្ខខណ្ឌតម្រូវអប្បបរមាដែលថា ដោយបដិសេធលើសំណើសុំស្ដាប់ចម្លើយសាក្សីជាថ្មី ស.ច.ស នឹងមិនអាចបញ្ចូលទៅក្នុងដីកាដំណោះស្រាយនូវអង្គហេតុសំខាន់ៗ ដែលគាំទ្រដល់ការកំណត់បទចោទនៃបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ឡើយ។ ក្នុងករណីនេះ ស.ច.ស បានប្រកាសថា ការស្ដាប់ចម្លើយសាក្សីសារជាថ្មីនោះ មិនមែនជាការចាំបាច់ទេ។ នេះមិនបង្កើតឱ្យមានកំហុសអង្គច្បាប់ ដែលអាចបង្ហាញឱ្យឃើញទេ។ ហេតុដូច្នេះមូលដ្ឋានរងនៃបណ្ដឹងឧទ្ធរណ៍នេះ ត្រូវបានច្រានចោល។

*៤. សាក្សី* [redacted]

៣០. ដើមបណ្ដឹងឧទ្ធរណ៍យោងទៅលើករណីដែលថា នៅពេល លោក [redacted] ត្រូវបានសួរឱ្យពណ៌នាពីស្ថានភាពរស់នៅ និងស្ថានភាពការងារនៅក្នុងរបបខ្មែរក្រហមពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ គាត់បានអះអាងដោយខ្លួនឯងថា ទាក់ទងទៅនឹងការរៀបការ "គេរៀបការម្ដង មាន ២០០គូ ឬ ១០០គូ ឬ ៥០គូ។ មនុស្សទាំងនោះ គ្មានសិទ្ធិក្នុងការជ្រើសរើសស្វាមី/ភរិយារបស់

---

[៧៧] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ២១ ដែលរាយសំណួរដូចៗគ្នាមាននៅក្នុងកថាខណ្ឌ ១៩ ទាក់ទងនឹងសាក្សីមុន លើបញ្ហាស្ថានភាពនៃការរៀបការ ហើយត្រូវបានដកស្រង់ឡើងវិញនៅក្នុងកថាខណ្ឌ ២៦ នៃសាលដីកានេះ។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

ខ្លួននោះទេ។ អង្គការជាអ្នកជ្រើសរើសស្វាមី/ភរិយាឱ្យ។ មានពិធីអបអរសម្រាប់ពួកគេ ដ៏តិចតួចមួយតែប៉ុណ្ណោះ"[៧៨]។ដើមបណ្តឹងឧទ្ធរណ៍សង្កត់ធ្ងន់ថា នៅក្នុងករណីនេះ ក៏ដូចនៅក្នុងបទសម្ភាសន៍ដំបូងៗរបស់ ស.ច.ស ដែរ ប្រសិនបើសាក្សីណាមួយរៀបរាប់ពីបញ្ហាកម្មវត្ថុនេះដោយខ្លួនឯងនោះ មិនមានការចោទសួរបន្ថែមណាមួយត្រូវបានធ្វើឡើង ដើម្បីបង្កើតនូវធាតុផ្សំនៃបទឧក្រិដ្ឋទេ។ ដើមបណ្តឹងឧទ្ធរណ៍អះអាងថា យ៉ាងហោចណាស់ សាក្សីទាំងនោះគួរត្រូវបានសួរអំពីពេលវេលា និងទីកន្លែងនៃការរៀបការដែលបានពណ៌នា ដើម្បីអាចធ្វើការចោទប្រកាន់ពីបទណាមួយបាន។ នៅក្នុងករណីជាក់លាក់មួយនេះ ដើមបណ្តឹងឧទ្ធរណ៍អះអាងថា សាក្សីគួរត្រូវបានសួរ ថាតើខ្លួនចង់មានន័យដូចម្តេចចំពោះពាក្យ "ពួកគេ" និងពាក្យ "អង្គការ"[៧៩]។

៣១. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សំណួររបស់អ្នកស៊ើបអង្កេតមានចំនួនតិចជាងការសួរទៅលោក [redacted] កាលពីលើកមុន។ អង្គបុរេជំនុំជម្រះយល់ស្របថា អ្នកស៊ើបអង្កេតប្រហែលជាអាចសួរសាក្សីនូវសំណួរបន្ថែមអំពីបញ្ហារៀបការ និងសំណួរបន្តបន្ទាប់ទៀត។ ប៉ុន្តែការពិតដែលថា សាក្សីមួយចំនួនមិនត្រូវបានសួរពីបញ្ហានេះ ហើយថា ស.ច.ស យល់ឃើញថា មិនជាការចាំបាច់ដើម្បីស្តាប់ចម្លើយពួកគាត់សារជាថ្មី មិនបានបង្កើតកំហុសអង្គច្បាប់ទេ។ ដូចអះអាងរួចមកហើយ ស.ច.ស មានឆន្ទានុសិទ្ធិទូលាយ ក្នុងការសម្រេចលើសំណើសុំឱ្យមានការបំពេញកិច្ចស៊ើបសួរ ហើយ ស.ច.ស ស្ថិតក្នុងស្ថានភាពដ៏ប្រសើរបំផុតដើម្បីវាយតម្លៃ ថាតើត្រូវដឹកនាំ ឬមិនដឹកនាំកិច្ចនោះ ដោយពិចារណាទៅលើភារកិច្ចទូទៅ និងការយល់ដឹងរបស់ខ្លួនទៅលើសំណុំរឿង។ ហេតុដូច្នេះ នៅក្នុងស្ថានភាពទាំងនេះ វានឹងមិនសមស្របសម្រាប់អង្គបុរេជំនុំជម្រះអនុវត្តឆន្ទានុសិទ្ធិជំនួស ស.ច.ស នោះទេ។

៣២. ដើម្បីបង្ហាញថា ស.ច.ស មានកំហុសក្នុងការសម្រេចថា ការស្តាប់ចម្លើយសាក្សីសារជាថ្មីមិនមែនជាការចាំបាច់នោះ ដើមបណ្តឹងឧទ្ធរណ៍ត្រូវបង្ហាញថា ដោយបដិសេធមិនស្តាប់ចម្លើយសាក្សីជាថ្មីនោះ ស.ច.ស នឹងមិនអាចបញ្ចូលទៅក្នុងដីកាដំណោះស្រាយនូវអង្គហេតុសំខាន់ៗដែលគាំទ្រដល់ការកំណត់បទចោទនៃបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ឡើយ។ លក្ខខណ្ឌនេះ

[៧៨] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២២ ដោយយោងទៅលើឯកសារ D125/29 ទំព័រ ៤។

[៧៩] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៣ ដោយយោងទៅលើបន្ទាត់តែមួយនៃសំណួរដែលត្រូវ[illegible]ដោយសាក្សីពីរនាក់ មុន។ *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីជំទាស់ដីកាបដិសេធសំណើ[illegible]ស៊ើបសួរ* សាក្សីដែល*មានឈ្មោះនៅក្នុងសំណើសុំឱ្យមានកិច្ចស៊ើបសួរលើការរៀបអាពា[illegible]ដោយបង្ខំ*

00568540



តម្រូវឱ្យមានការវិភាគភស្តុតាងដែលមានរួចជាស្រេចនៅក្នុងសំណុំរឿង ទាក់ទងនឹងធាតុផ្សំដែលត្រូវបង្កើតឡើងសម្រាប់បទឧក្រិដ្ឋ ដែលត្រូវបានចោទប្រកាន់។ ដើមបណ្តឹងឧទ្ធរណ៍អះអាងថា បទសម្ភាសន៍ដែលមានរួចមកហើយ មិនបង្កើតឱ្យបាននូវអង្គហេតុសំខាន់ៗពាក់ព័ន្ធ និងមិននាំឱ្យមានការកំណត់បទចោទនៃអង្គហេតុទាំងនោះទេ[៨០]។ ដើមបណ្តឹងឧទ្ធរណ៍មិនបានបង្ហាញពីការអះអាងនេះ ពីព្រោះខ្លួនមិនបានវិភាគភស្តុតាង ដែលបានប្រមូលរួចហើយ និងមិនបានកំណត់អត្តសញ្ញាណជាក់លាក់នៃធាតុផ្សំបទឧក្រិដ្ឋដែលមិនទាន់មាននៅឡើយ ដែលដើមបណ្តឹងឧទ្ធរណ៍ត្រូវបង្ហាញថា តើការស្តាប់ចម្លើយសាក្សីជាក់លាក់ទាំងនោះ អាចជួយដល់ការបង្កើតនូវអង្គហេតុសំខាន់ៗពាក់ព័ន្ធបានដោយរបៀបណា។ ហេតុដូច្នេះ ដើមបណ្តឹងឧទ្ធរណ៍ខកខានក្នុងការបង្ហាញថា ស.ច.ស មានកំហុសដោយពិចារណាឃើញថា ការស្តាប់ចម្លើយសាក្សីនេះសារជាថ្មីមិនមែនជាការចាំបាច់។ ដូច្នេះ មូលដ្ឋានរងនៃបណ្តឹងឧទ្ធរណ៍នេះ ត្រូវបានច្រានចោល។

*៥. សាក្សី [redacted]*

៣៣. ដើមបណ្តឹងឧទ្ធរណ៍យោងទៅលើការរៀបរាប់ភ្លាមៗរបស់ លោក [redacted] ទាក់ទងនឹងករណីរំលោភសេពសន្ថវៈ ក្នុងអំឡុងពេលស្តាប់ចម្លើយរបស់គាត់ កាលពីថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០០៨ នៅពេលសួរពីស្ថានភាពឃុំខ្លួនរបស់គាត់ដោយពួកខ្មែរក្រហម នៅមន្ទីរសន្តិសុខភូមិភាគឧត្តរ។ គាត់បានពណ៌នាពីអង្គហេតុដូចខាងក្រោម៖ "ក្មេងស្រីម្នាក់ដែលជាចុងភៅត្រូវបានឆ្មាំយាមរំលោភ។ នាងត្រូវគេសម្រាតសម្លៀកបំពាក់អស់។ ខ្លួនប្រាណនាងស្រាតនទល ហើយនាងត្រូវគេសម្លាប់ដោយវះពោះយកថ្លើមធ្វើជាអាហារ"[៨១]។ ដើមបណ្តឹងឧទ្ធរណ៍សង្កត់ធ្ងន់ថា អ្នកស៊ើបអង្កេតមិនបានសួរសំណួរអ្វីអំពីការរំលោភនេះឡើយ ដែលការពិតទៅ ក្នុងទស្សនៈរបស់ដើមបណ្តឹងឧទ្ធរណ៍ លោក [redacted] "ហាក់ដូចជា" សាក្សីដែលបានឃើញហេតុការណ៍ដោយផ្ទាល់ភ្នែក[៨២]។ ដើមបណ្តឹងឧទ្ធរណ៍អះអាងថា ដោយសារតែសាក្សីមិនមែនជាមន្ត្រីតុលាការ ចាំបាច់ត្រូវមានព័ត៌មានបន្ថែមទៀតអំពីអង្គហេតុជាក់លាក់ និងស្ថានភាពទាំងនោះ ដើម្បីគាំទ្រដល់ការចោទ

---

[៨០] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១៤។

[៨១] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៤។

[៨២] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៥។



E.C.C.C * C.E.T.C
PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE

ប្រកាន់ពីបទរំលោភសេពសន្ធវៈ។ ដើមបណ្ដឹងឧទ្ធរណ៍ ផ្ដល់ឱ្យនូវបញ្ជីមួយដែលរៀបរាប់ពីសំណួរ ពាក់ព័ន្ធ ដែលអាចត្រូវបានសួរទៅកាន់សាក្សីឱ្យបំភ្លឺពីស្ថានភាពទាំងនេះ[៨៣]។

៣៤. អង្គបុរេជំនុំជម្រះបានពិនិត្យទៅលើសេចក្ដីអះអាងពាក់ព័ន្ធរួចហើយ។ ការអះអាងថា បុគ្គលដែលត្រូវបានសម្ភាសន៍នោះ គឺជាសាក្សីដែលបានឃើញព្រឹត្តិការណ៍ផ្ទាល់ភ្នែក មិនមានលក្ខណៈគ្រប់គ្រាន់ទេ។ តាមការពិត បុគ្គលនោះអះអាងថា គាត់និងអ្នកទោសដទៃទៀតដែលមានជំនាញបច្ចេកទេស ត្រូវបានចាត់តាំងឱ្យទៅធ្វើការតាមជំនាញ ហើយគាត់គ្រប់គ្រងការជួសជុល [redacted] និង [redacted] ខណៈពេលដែលអ្នកទោសស្រីពីរនាក់ទៀតត្រូវបានចាត់តាំងឱ្យធ្វើជា [redacted][៨៤]។ មិនមានចំណុចណាអាចឱ្យយល់បានថា គាត់ប្រាកដជាមានវត្តមាននៅកន្លែង ដែលមានការរំលោភសេពសន្ធវៈ និងថាតើការអះអាងនេះគឺជាការឮតាមគ្នា ឬយ៉ាងណានោះទេ។ ប៉ុន្តែ ការធ្វើសេចក្ដីសន្និដ្ឋានទៅលើចំណុចនេះ មិនមែនជាការចាំបាច់ឡើយ ពីព្រោះដើមបណ្ដឹងឧទ្ធរណ៍មិនបានបង្ហាញថា ដោយបដិសេធមិនស្ដាប់ចម្លើយសាក្សីជាថ្មីម្ដងទៀត ស.ច.ស នឹងមិនអាចបញ្ចូលទៅក្នុងដីកាដំណោះស្រាយនូវអង្គហេតុសំខាន់ៗ ដែលគាំទ្រដល់ការកំណត់បទចោទនៃបទឧក្រិដ្ឋរំលោភសេពសន្ធវៈ ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបានទេ។ លើសពីនេះ ការបដិសេធរបស់សហចៅក្រមស៊ើបអង្កេតមិនសម្ភាសន៍សាក្សីនេះជាថ្មីម្ដងទៀត ដោយហេតុថា សាក្សីនេះត្រូវបានសម្ភាសន៍រួចហើយ ត្រូវតែពិចារណាស្របគ្នាជាមួយភស្តុតាងផ្សេងទៀត ដែល ស.ច.ស មានពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋរំលោភសេពសន្ធវៈ[៨៥]។ ចំពោះចំណុចនេះ អង្គបុរេជំនុំជម្រះយោងទៅលើការអះអាងរបស់ដើមបណ្ដឹងឧទ្ធរណ៍ ដើម្បីគាំទ្រសំណើទីពីរ និងទីបីរបស់ខ្លួន។ អង្គបុរេជំនុំជម្រះសង្កេតឃើញថា បុគ្គលពីររូបក្នុងចំណោមបុគ្គលដែលត្រូវបានសម្ភាសន៍ ពណ៌នាថា បានជួបប្រទះដោយផ្ទាល់ចំពោះការរំលោភសេពសន្ធវៈ ឬអំពើហិង្សាផ្លូវភេទដទៃទៀត[៨៦]។ បុគ្គលម្នាក់ក្នុងចំណោមអ្នកទាំងពីរនេះ ផ្ដល់ព័ត៌មានលម្អិតអំពីប្រភេទនៃអំពើហិង្សាផ្លូវភេទ ដែលបានចោទ

---

[៨៣] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ២៥-២៦។

[៨៤] ឯកសារ D125/33 ទំព័រ ៥។

[៨៥] សូមមើលដីកាសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ១៧។

[៨៦] ឯកសារ D125/87 ទំព័រ ៧ (ភាសាបារាំង)។ ឯកសារ D22/30/1 ទំព័រ ១។

អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER * CHAMBRE PRÉLIMINAIRE * E.C.C.C * C.E.T.C

ប្រកាន់ និងស្ថានភាពជុំវិញព្រឹត្តិការណ៍នោះ[៨៧] ខណៈពេលដែលបុគ្គលមួយរូបទៀតរៀបរាប់ថា ខ្លួនត្រូវបានរំលោភសេពសន្ថវៈយ៉ាងព្រៃផ្សៃ និងត្រូវបានវាយដំនៅហ្នឹងកន្លែងដែលនារីទាំងអស់ផ្សេងទៀតត្រូវបានរំលោភម្នាក់ម្ដងៗដោយទាហានខ្មែរក្រហម ហើយត្រូវបានសម្លាប់ សូម្បីតែស្ត្រីមានផ្ទៃពោះក៏ដោយ។ សាក្សីនោះពន្យល់ពីការរត់គេចខ្លួនរបស់គាត់ ដែលអាចឱ្យគាត់រួចផុតពីការសម្លាប់បាន[៨៨]។ បុគ្គលផ្សេងទៀត ដែលត្រូវបានសម្ភាសន៍រាយការណ៍ថា ការរំលោភសេពសន្ថវៈត្រូវបានប្រព្រឹត្តនៅកន្លែងឃុំឃាំង ហើយពួកគាត់បញ្ជាក់ច្បាស់ថា សក្ខីកម្មរបស់គាត់បានមកពីការឮតាមគ្នា[៨៩]។ សាក្សីម្នាក់ក្នុងចំណោមសាក្សីទាំងនោះ ទំនងជាសាក្សីដែលបានឃើញព្រឹត្តិការណ៍ផ្ទាល់ភ្នែក[៩០] ទន្ទឹមនឹងនេះ សាក្សីដទៃទៀតមិនបានបញ្ជាក់ពីមូលដ្ឋាននៃការដឹងឮរបស់ពួកគាត់ឡើយ[៩១]។ ចម្លើយសាក្សីមួយចំនួនទៀត រៀបរាប់ពីអំពើខុសសីលធម៌នានា រវាងពួកអ្នកយាមនិងអ្នកទោសស្រីៗ ក៏ដូចជាកម្មករនៅតាមកងផងដែរ។ ចម្លើយសាក្សីនោះក៏បានរៀបរាប់ពីការដាក់ទណ្ឌកម្មលើអំពើខុសសីលធម៌ទាំងនោះ[៩២]។ តាមការពិនិត្យនេះ អង្គបុរេជំនុំជម្រះ

---

[៨៧] ឯកសារ D125/87 ទំព័រ ៧ (ផ្នែកភាសាបារាំង)។

[៨៨] ឯកសារ D22/30/1 ទំព័រ ១។

[៨៩] ឯកសារ D25/17 ទំព័រ ៣ សាក្សីដែលបានឮពីការរំលោភសេពសន្ថវៈ ដែលប្រព្រឹត្តដោយប្រធានគុក (ឥឡូវស្លាប់) និងអ្នកផ្សេងទៀតចំពោះអ្នកទោសស្រីៗ។ ឯកសារ D125/187 ទំព័រ ៥ សាក្សីដែលបានឮពីបុគ្គលម្នាក់ដែលឥឡូវស្លាប់ហើយនោះ និងពីម្នាក់ទៀតដែលនៅរស់ ថាកងទ័ពខ្មែរក្រហមរំលោភសេពសន្ថវៈស្ត្រីក្មេងៗ [redacted]របស់ស្ត្រីទាំងនោះ ព្យួរហាលពួកគាត់នៅក្រោមដើមក្រសាំងមួយ ហើយសម្លាប់ចោល។

[៩០] ឯកសារ D125/23 ទំព័រ១១ សាក្សីដែលបានរាយការណ៍ថាអ្នកទោសមួយចំនួនត្រូវបានរំលោភសេពសន្ថវៈ ហើយសម្លាប់ដោយអ្នកយាម រួមមានអ្នកដែលមានឈ្មោះម្នាក់ ដែលក្រោយមកអ្នកយាមនោះឱ្យគាត់ (សាក្សី) ទៅមើល និងកប់ស្ត្រីទាំងនោះ ហើយថា គាត់បានឃើញអ្នកទោសមួយចំនួនត្រូវបានសម្រាតខោអាវ ហើយគេយកគ្រាប់ M79 [redacted] របស់ពួកគាត់។

[៩១] ឯកសារ D125/108 និងឯកសារ D108/3/3។

[៩២] ឯកសារ D125/134 ទំព័រ ៦ ដែលយោងទៅលើការចាប់ខ្លួនរបស់ប្រធានគុកនោះដោយមូលហេតុនេះ។ ឯកសារ D166/34 ទំព័រ៣ដែលយោងទៅលើហេតុការណ៍មួយចំនួនរួមមានការសម្លាប់កម្មករប្រុសម្នាក់និងស្រីម្នាក់ដោយមូលហេតុខុសសីលធម៌។ សូមមើលផងដែរ ឯកសារ D166/37 ទំព័រ ៦ និងឯកសារ D166/39 ទំព័រ ៤ ទាក់ទងនឹងកម្មករស្រីៗដែលត្រូវបានចោទថាបានប្រព្រឹត្តខុសសីលធម៌ ដោយគ្មានភាពច្បាស់លាស់ជាងនេះ ក៏ដូចជាឯកសារ D125/118 ដែលគាត់បានចូលរួមក្នុង *សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណីជំទាស់ដីកាប[illegible]បំពេញកិច្ចស៊ើបសួរ* សាក្សីដែល*មានឈ្មោះនៅក្នុងសំណើសុំឱ្យមានកិច្ចស៊ើបសួរលើការ[illegible]និងការបាត់ខ្លួនដោយបង្ខំ*

មិនយល់ឃើញថា ស.ច.ស មានកំហុសក្នុងការបដិសេធមិនស្តាប់ចម្លើយសាក្សីជាថ្មីម្តងទៀតនោះទេ។ ហេតុដូច្នេះ មូលដ្ឋានរងនៃបណ្តឹងឧទ្ធរណ៍នេះ ត្រូវបានច្រានចោល។

៣៥. ទាក់ទងនឹងការជំទាស់តវ៉ាផ្សេងទៀត ដែលបានលើកឡើងនៅក្នុងមូលដ្ឋាននេះនៃបណ្តឹងឧទ្ធរណ៍ អង្គបុរេជំនុំជម្រះសូមធ្វើការសង្កេតដូចតទៅ។ ដើមបណ្តឹងឧទ្ធរណ៍អះអាងមិនត្រឹមត្រូវទេដែលថា លេខយោងជើងទំព័រដែលមាននៅក្នុងសំណើទីពីរ និងទីបួន[៩៣] រៀបរាប់ពីចម្លើយសាក្សីពេញលេញទាក់ទងនឹងប្រធានបទនេះ[៩៤]។ ផ្ទុយទៅវិញ លេខយោងជើងទំព័រនៅក្នុងសំណើទីពីរ មានសេចក្តីដកស្រង់ ឬការរៀបពាក្យឡើងវិញ ដែលបានមកពីសាក្សី [redacted] ក្នុងចំណោមសាក្សី [redacted] នាក់ដែលត្រូវបានស្នើសុំឱ្យស្តាប់ចម្លើយសារជាថ្មី។ ស្រដៀងគ្នានេះដែរ ក្រៅពីសាក្សីដែលបានរៀបរាប់ខាងលើ សំណើទីបីមិនបានរៀបរាប់ "ចម្លើយសាក្សីពេញលេញលើប្រធានបទនេះ" ទេ ពីព្រោះលេខយោងជើងទំព័រនៃបណ្តឹងឧទ្ធរណ៍ ផ្តល់ឱ្យតែការរៀបពាក្យឡើងវិញសង្ខេបខ្លីមួយនៃចម្លើយសាក្សី ទាក់ទងទៅនឹងការរៀបការដោយបង្ខំ ឬបទឧក្រិដ្ឋពាក់ព័ន្ធផ្លូវភេទ។ ដើមបណ្តឹងឧទ្ធរណ៍មិនបានព្យាយាមបង្ហាញថា ស.ច.ស អាចមានកំហុសក្នុងការបដិសេធសំណើសុំស្តាប់ចម្លើយសាក្សីម្នាក់ៗក្នុងចំណោមសាក្សីទាំងនេះជាថ្មីម្តងទៀត។ ដើមបណ្តឹងឧទ្ធរណ៍អះអាងថា "សក្ខីកម្មរបស់សាក្សី និងជនរងគ្រោះទាំងអស់ ដែលមាននៅក្នុងសំណុំរឿងនាពេលបច្ចុប្បន្ននេះ សាក្សី និងជនរងគ្រោះ ដែលត្រូវបានស្នើឱ្យមានការស្តាប់ចម្លើយឡើងវិញនោះ នៅមិនទាន់គ្រប់គ្រាន់ទេសម្រាប់បទឧក្រិដ្ឋរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងបទឧក្រិដ្ឋពាក់ព័ន្ធផ្លូវភេទ។" ពីព្រោះចម្លើយសាក្សីទាំងនោះ "មិនមានផ្ទុកព័ត៌មានគ្រប់គ្រាន់ ដែលតម្រូវឱ្យមានសម្រាប់ធាតុផ្សំបទឧក្រិដ្ឋ នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ (ការប៉ុនប៉ង)រំលោភសេពសន្ថវៈ ការដាក់ជាទាសករ(ផ្លូវភេទ) និង (ការប៉ុនប៉ង)ធ្វើឱ្យមានផ្ទៃពោះដោយបង្ខំ។ ចម្លើយសាក្សីទាំងនោះ ក៏មិនបានបញ្ជាក់ប្រាប់ពី

---

ការកាត់សេចក្តីអ្នកដែលត្រូវបានចោទថាបានប្រព្រឹត្តខុសសីលធម៌។ បើទោះជាសាក្សីនេះត្រូវបានស្តាប់ចម្លើយដោយលម្អិតស្តីពីការកាត់សេចក្តីនេះក៏ដោយ ក៏គ្មានសំណួរណាត្រូវចោទសួរទៅគាត់អំពីអង្គហេតុដែលជាមូលដ្ឋាននៃការចោទប្រកាន់ពីបទខុសសីលធម៌ទេ។

[៩៣] ដើមបណ្តឹងឧទ្ធរណ៍យោងលើសំណើទីបួន ដែលនៅក្នុងសាលដីកានេះ ត្រូវបានចាត់ទុកថាជាសំណើទីបី។

[៩៤] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៧។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

លក្ខណៈ ដែលបទឧក្រិដ្ឋទាំងនោះ ត្រូវបានប្រព្រឹត្តឡើងជាប្រព័ន្ធ និងជាទូទៅនោះដែរ”[៥៥]។ លក្ខខណ្ឌនេះគឺជាអ្វីដែលដើមបណ្ដឹងឧទ្ធរណ៍ត្រូវបង្ហាញឱ្យឃើញ នៅពេលធ្វើការចោទប្រកាន់ថា ស.ច.ស មានកំហុសអង្គច្បាប់ កំហុសអង្គហេតុ ឬរំលោភអំណាចឆន្ទានុសិទ្ធិរបស់ខ្លួន ពេលបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរណាមួយ។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះច្រានចោលចំណុចនៃមូលដ្ឋានទីមួយនៃបណ្ដឹងឧទ្ធរណ៍នេះ ដោយមិនចាំបាច់ធ្វើការពិចារណាបន្ថែមលើអង្គសេចក្ដី។ បន្តទៅនេះ អង្គបុរេជំនុំជម្រះនឹងពិនិត្យទៅលើមូលដ្ឋានទីពីរនៃបណ្ដឹងឧទ្ធរណ៍។

## ខ. មូលដ្ឋានទីពីរនៃបណ្ដឹងឧទ្ធរណ៍៖ ការបដិសេធមិនត្រឹមត្រូវលើសំណើ ដោយសារលើកសំអាងហេតុថា អង្គហេតុដែលត្រូវបានស្នើសុំឱ្យស៊ើបអង្កេតនោះ មិនស្ថិតនៅក្នុងវិសាលភាពនៃការស៊ើបអង្កេត

៣៦. ដោយផ្អែកលើមូលដ្ឋានទីពីរនៃបណ្ដឹងឧទ្ធរណ៍ ដើមបណ្ដឹងឧទ្ធរណ៍ចោទប្រកាន់ថា ដីកាសម្រេចដែលត្រូវបានជំទាស់ ផ្អែកលើការបកស្រាយមិនត្រឹមត្រូវលើច្បាប់ជាធរមាន ពីព្រោះដីកាសម្រេចនេះបដិសេធសំណើ ដោយផ្អែកលើមូលដ្ឋានមិនត្រឹមត្រូវ ដែលថា អង្គហេតុដែលត្រូវស្នើសុំឱ្យស៊ើបអង្កេត មិនស្ថិតនៅក្នុងវិសាលភាពនៃការស៊ើបអង្កេត ឬថា សំណើទាំងនោះមិនបានបង្ហាញឱ្យច្បាស់ថា អង្គហេតុនោះស្ថិតនៅក្នុងវិសាលភាពនៃការស៊ើបអង្កេត[៥៦]។ ជាក់លាក់ជាងនេះទៅទៀត ដើមបណ្ដឹងឧទ្ធរណ៍យោងទៅលើការរកឃើញក្នុងដីកាសម្រេច ដែលត្រូវបានជំទាស់ថា អង្គហេតុដែលផ្ដល់ឱ្យដោយបុគ្គលមួយចំនួន ដែលត្រូវបានស្នើសុំឱ្យស្ដាប់ចម្លើយសារជាថ្មីនោះ ស្ថិតនៅក្រៅវិសាលភាពនៃការស៊ើបអង្កេត[៥៧] ឬថា មិនមានការបង្ហាញឱ្យច្បាស់ថា អង្គហេតុទាំងនោះស្ថិតនៅក្នុងវិសាលភាពនៃការស៊ើបអង្កេត[៥៨]។ ដើមបណ្ដឹងឧទ្ធរណ៍លើកទឡ្ហីករណ៍ថា មាត្រា ១២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងវិធាន៥៥(២) នៃវិធានផ្ទៃក្នុង ដែលចែងថា ស.ច.ស ត្រូវស៊ើបអង្កេតតែអង្គហេតុទាំងឡាយណា ដែលមាននៅក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួរប៉ុណ្ណោះ

[៥៥] *ដូចដើងទំព័រខាងលើ។*

[៥៦] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៣០-៤៣។

[៥៧] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៣០ ដោយយោងមិនផ្ទាល់ទៅលើដីកាដែលត្រូវបានជំទាស់ កថាខណ្ឌ ៩, ១១។

[៥៨] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៣០ ដោយយោងមិនផ្ទាល់ទៅលើដីកាដែលត្រូវបានជំទាស់ កថាខណ្ឌ ៧, ១០, ១៦។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

នោះ គឺសំដៅទៅលើអង្គហេតុទាំងមូល។ ដើមបណ្ដឹងឧទ្ធរណ៍លើកទឡ្ហីករណ៍បន្ថែមដែរថា គ្មានបទបញ្ញត្តិណាមួយនៃលិខិតុបករណ៍ទាំងនេះ កំរិតនូវវិសាលភាពនៃការស៊ើបអង្កេតចំពោះអង្គហេតុនានា នៃផ្នែកខ្លះ ឬវគ្គខ្លះ នៃដីកាបញ្ជូនរឿងឱ្យស៊ើបសួរ[៩៩]។ ដើមបណ្ដឹងឧទ្ធរណ៍ យោងបន្ថែមផងដែរលើមាត្រា៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងវិធាន៥៣(១) នៃវិធានផ្ទៃក្នុង ដែលចែងថា ដីកាបញ្ជូនរឿងឱ្យស៊ើបសួរត្រូវមានសេចក្ដីសង្ខេបអង្គហេតុ ហើយដើមបណ្ដឹងឧទ្ធរណ៍លើកទឡ្ហីករណ៍ថា សាក្សីទាំងអស់ដែលការសម្ភាសន៍ជាមួយពួកគាត់ត្រូវបានបដិសេធ មានពាក់ព័ន្ធទៅនឹងអង្គហេតុដែលមាននៅក្នុងផ្នែកនៃដីកាបញ្ជូនរឿងឱ្យស៊ើបសួរ ក្រោមចំណងជើងថា "សេចក្ដីសង្ខេបអង្គហេតុ"។ ហេតុដូច្នេះ សាក្សីទាំងនេះគឺជាផ្នែកមួយនៃវិសាលភាពនៃការស៊ើបអង្កេត[១០០]។

៣៧. សហព្រះរាជអាជ្ញាបានបំភ្លឺរួចមកហើយចំពោះពាក្យពេចន៍នៅក្នុងកថាខណ្ឌ ១២២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ សហព្រះរាជអាជ្ញាបានអះអាងថា "កិច្ចស៊ើបសួរដែលបានស្នើសុំ គឺមិនកំរិតត្រឹមតែអង្គហេតុទាំងឡាយដូចបានកំណត់នៅក្នុង កថាខណ្ឌ ៣៧ ដល់កថាខណ្ឌ ៧២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងក្នុងកថាខណ្ឌ ៥ ដល់កថាខណ្ឌ ២០ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមប៉ុណ្ណោះទេ ក៏ប៉ុន្តែវាលាតសន្ធឹងដល់គ្រប់អង្គហេតុទាំងអស់ ដែលបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានទាំងពីរនេះ *ក្នុងករណីដែល*អង្គហេតុទាំងនេះជាជំនួយនៅក្នុងការស៊ើបអង្កេត (ក) ធាតុផ្សំយុត្តាធិការដែលចាំបាច់ដើម្បីកំណត់ ថាតើ ស្ថានភាពនៃអង្គហេតុនានាដូចមានចែងក្នុងកថាខណ្ឌ ៣៧ ដល់ ៧២ និងកថាខណ្ឌ ៥ ដល់ ២០ បង្កើតបានជាបទឧក្រិដ្ឋ ដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ដែរឬទេ ឬ (ខ) ទម្រង់នៃការទទួលខុសត្រូវរបស់ជនសង្ស័យទាំងឡាយ ដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ"[១០១]។ នេះគឺជាសេចក្ដីសន្និដ្ឋានតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យរបស់ ស.ច.ស ចុះថ្ងៃទី០៨ ខែសីហា

[៩៩] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៣១។

[១០០] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៣៧។

[១០១] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ចំពោះសហចៅក្រមស៊ើបអង្កេត ដែលស្នើសុំឱ្យបញ្ជាក់អំពីវិសាលភាពនៃកិច្ចស៊ើបសួរដែលបានស្នើឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនិងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០៨ ឯកសារ D98/I កថាខណ្ឌ ២។



PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE

ឆ្នាំ២០០៨[១០២]។ ដើមបណ្តឹងឧទ្ធរណ៍អះអាងថាការកំណត់របស់សហព្រះរាជអាជ្ញានេះ មិនត្រូវបានគាំទ្រដោយក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងវិធានផ្ទៃក្នុងទេ[១០៣]។

៣៨. អង្គបុរេជំនុំជម្រះសូមទាញចំណាប់អារម្មណ៍មកលើប្រព័ន្ធអនុវត្តនីតិវិធី នៅ អ.វ.ត.ក ដែលច្បាប់ អ.វ.ត.ក[១០៤] និងវិធានផ្ទៃក្នុង ចែងថា សហព្រះរាជអាជ្ញាទទួលខុសត្រូវពេញលេញលើការផ្តួចផ្តើមបណ្តឹងអាជ្ញាចំពោះឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក តាមការសម្រេចចិត្តដោយឯកឯង ឬដោយផ្អែកតាមពាក្យបណ្តឹងណាមួយ[១០៥]។ សហព្រះរាជអាជ្ញាទទួលខុសត្រូវក្នុងការដឹកនាំកិច្ចស៊ើបសួរបឋម[១០៦] ហើយបើកកិច្ចស៊ើបសួរណាមួយដោយបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទៅ ស.ច.ស ប្រសិនបើសហព្រះរាជអាជ្ញាមានហេតុផលជឿជាក់ថាឧក្រិដ្ឋកម្ម ដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក បានកើតមានពិត[១០៧]។ ស.ច.ស ទទួលខុសត្រូវក្នុងការដឹកនាំកិច្ចស៊ើបសួរនេះ។ កិច្ចស៊ើបសួរនេះ ត្រូវបានកំណត់ត្រឹមតែឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក និងត្រូវបានកំណត់បន្ថែមទៀតលើអង្គហេតុដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និង/ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមតែប៉ុណ្ណោះ[១០៨]។ ផ្ទុយពីច្បាប់កម្ពុជា ជនរងគ្រោះណាមួយ ដែលមានបំណងតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខ អ.វ.ត.ក អាចធ្វើដូច្នេះបានតាមរយៈអន្តរាគមន៍ ដោយចូលរួមក្នុងកិច្ចដំណើរការនីតិវិធីដែលកំពុងបន្ត ដែលស្ថិតនៅក្នុងវិសាលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមតែប៉ុណ្ណោះ។ នេះគឺជាក្រមខណ្ឌការងារបច្ចុប្បន្ន

---

[១០២] ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៨ ឯកសារ D98។

[១០៣] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣៩។

[១០៤] ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ (នស/រកម/១០០៤/០០៦) ("ច្បាប់ អ.វ.ត.ក")។

[១០៥] វិធាន ៤៩(១) នៃវិធានផ្ទៃក្នុង។ សូមមើលផងដែរ មាត្រា ១៦ នៃច្បាប់ អ.វ.ត.ក ដែលទទួលស្គាល់សហព្រះរាជអាជ្ញាពីររូបក្នុងការធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់។

[១០៦] វិធាន ៥០ នៃវិធានផ្ទៃក្នុង។

[១០៧] វិធាន ៥៣(១) នៃវិធានផ្ទៃក្នុង។

[១០៨] វិធាន ៥៥(២) នៃវិធានផ្ទៃក្នុង។

ដែលរាល់កិច្ចស៊ើបសួរទាំងអស់ត្រូវប្រតិបត្តិតាម។ ហេតុដូច្នេះ ខណៈពេលដែលកថាខណ្ឌ (២) កថាខណ្ឌ (៣) និងកថាខណ្ឌ (១០) នៃវិធាន ៥៥ នៃវិធានផ្ទៃក្នុង អនុញ្ញាតឱ្យអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិស្នើសុំ ស.ច.ស ឱ្យចេញដីកាសម្រេច ឬបំពេញកិច្ចស៊ើបសួរ ដើម្បីដឹកនាំកិច្ចស៊ើបសួរនោះ សិទ្ធិនេះត្រូវបានកំណត់មកត្រឹមតែវិសាលភាពដូចរៀបរាប់ពីខាងលើប៉ុណ្ណោះ។ យោងលើក្របខណ្ឌការងារនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា ដើមបណ្តឹងឧទ្ធរណ៍មិនអាចអះអាងបានដោយជោគជ័យទេថា សេចក្តីសន្និដ្ឋានរបស់សហព្រះរាជ-អាជ្ញា មិនត្រូវបានគាំទ្រដោយក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ឬវិធានផ្ទៃក្នុងនោះ។ សហព្រះរាជ-អាជ្ញា គឺជាភាគីដែលទទួលខុសត្រូវក្នុងការកំណត់វិសាលភាពនៃកិច្ចស៊ើបសួរ។ កិច្ចស៊ើបសួរនេះត្រូវបង្កើតឱ្យបាននូវធាតុផ្សំបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ និងការទទួលខុសត្រូវរបស់ជនត្រូវចោទ ដើម្បីឱ្យធាតុផ្សំនិងការទទួលខុសត្រូវទាំងនេះ អាចត្រូវបានបញ្ចូលទៅក្នុងដីកាដំណោះស្រាយ។ ស.ច.ស បានប្រតិបត្តិត្រឹមត្រូវទៅតាមក្របខណ្ឌការងារនេះ នៅក្នុងការសម្រេចរបស់ខ្លួនថា អង្គហេតុដែលត្រូវបានចោទប្រកាន់នោះ មិនស្ថិតនៅក្នុងវិសាលភាពនៃកិច្ចស៊ើបសួរនោះទេ។ ស.ច.ស មិនមានកំហុសអង្គច្បាប់ឡើយ។ អង្គបុរេជំនុំជម្រះកត់សម្គាល់បន្ថែមទៀតថា ប្រសិនបើដើមបណ្តឹងឧទ្ធរណ៍បានបង្ហាញឱ្យគ្រប់គ្រាន់ថា ភស្តុតាងដែលស្នើឡើងនោះ អាចបញ្ជាក់ពី"ធាតុផ្សំផ្នែកយុត្តាធិការចាំបាច់សម្រាប់ការបង្កើតឱ្យមានថាតើ ស្ថានភាពអង្គហេតុ ដូចរៀបរាប់នៅក្នុងកថាខណ្ឌ ៣៧ ដល់ ៧២ នាំឱ្យមានឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក" ជាជាងការអះអាងដ៏សាមញ្ញថា ភស្តុតាងនឹងនាំឱ្យមានដូច្នេះនោះ អង្គបុរេជំនុំជម្រះអាចនឹងសម្រេចផ្ទុយពីនេះ។

## គ. មូលដ្ឋានទីបីនៃបណ្តឹងឧទ្ធរណ៍៖ ការបដិសេធមិនត្រឹមត្រូវលើសំណើ ដោយសារ ស.ច.ស មិនអាចកំណត់អត្តសញ្ញាណ និងស្វែងរកបុគ្គលដែលត្រូវស្តាប់ចម្លើយ

៣៩. ផ្អែកលើមូលដ្ឋាននេះនៃបណ្តឹងឧទ្ធរណ៍ ដើមបណ្តឹងឧទ្ធរណ៍ធ្វើការចោទប្រកាន់ថា ដីកាសម្រេចដែលត្រូវបានជំទាស់នោះ ផ្អែកលើការបកស្រាយមិនត្រឹមត្រូវមួយទៅលើច្បាប់ជាធរមាន ដោយសារ ស.ច.ស បដិសេធសំណើសុំស្តាប់ចម្លើយសាក្សីមួយចំនួនសារជាថ្មី លើបញ្ហារៀបការដោយបង្ខំ និងបទឧក្រិដ្ឋពាក់ព័ន្ធផ្លូវភេទដទៃទៀត។ ស.ច.ស សម្រេចបដិសេធសំណើនេះដោយ



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

ផ្អែកលើមូលដ្ឋានថា ខ្លួនមិនអាចរកបានព័ត៌មានលម្អិតគ្រប់គ្រាន់ដើម្បីសម្រួលដល់ការកំណត់អត្តសញ្ញាណ និងទីកន្លែងបាន[១០៩]។ ដើមបណ្តឹងឧទ្ធរណ៍អះអាងថា ដីកាសម្រេចដែលត្រូវបានជំទាស់មិនធ្វើឡើងស្របតាមមាត្រា ១៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុងទេ ដែលតម្រូវឱ្យមាន "សេចក្តីសម្រេចដោយមានសំអាងហេតុ"មួយ ហើយដែលបង្កប់ន័យថា សំអាងទាំងនោះត្រូវមានលក្ខណៈក្បោះក្បាយ និងអាចតាមដានរកឃើញ ក៏ដូចជាការតម្រូវតាមវិធាន ២១(១)(ក) និង (គ) នៃវិធានផ្ទៃក្នុង ទាក់ទងទៅនឹងសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីផងដែរ[១១០]។ ដើមបណ្តឹងឧទ្ធរណ៍អះអាងថា ដីកាសម្រេចដែលត្រូវបានជំទាស់នេះមិនបានពន្យល់បន្ថែមទៅលើកិច្ចប្រឹងប្រែងដែលបានធ្វើឡើង ដើម្បីស្វែងរកសាក្សីដែលជាកម្មវត្ថុនៃសំណើនោះទេ។ ដើមបណ្តឹងឧទ្ធរណ៍បានធ្វើការ "សាកល្បង"មួយ ហើយផ្ញើសារអេឡិចត្រូនិចទៅលោក [redacted] នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ("DC-Cam") ហើយអះអាងថា ខ្លួនមានភាពងាយស្រួលក្នុងការទទួលបាននូវព័ត៌មានពីទីកន្លែងរបស់សាក្សីពីររូបក្នុងចំណោមសាក្សីដែលមាននៅក្នុងបញ្ជីស្នើនោះ[១១១]។

៤០. អង្គបុរេជំនុំជម្រះយល់ឃើញថា ទឡ្ហីករណ៍របស់ដើមបណ្តឹងឧទ្ធរណ៍មិនត្រឹមត្រូវ លើមូលដ្ឋានចំនួនពីរ៖ (ក) ទឡ្ហីករណ៍នេះមានភាពមិនពិតដោយធ្វើការសន្និដ្ឋានថា ស.ច.ស មិនបានព្យាយាមកំណត់ទីកន្លែងរបស់សាក្សី ដោយសារតែដើមបណ្តឹងឧទ្ធរណ៍ អាចស្វែងរកសាក្សីពីរនាក់ក្នុងចំណោមសាក្សីទាំងនោះដោយភាពងាយស្រួល។ សេចក្តីសន្និដ្ឋានដូចគ្នា ប៉ុន្តែ មានលក្ខណៈចោទប្រកាន់តិចជាងនេះគឺថា ស.ច.ស ពិតជាបានធ្វើការស្រាវជ្រាវ ប៉ុន្តែ ការស្រាវជ្រាវនេះមិនគ្រប់គ្រាន់ ហើយ(ខ) កថាខណ្ឌទី ១៦ ដល់ ១៨ នៃដីកាសម្រេចដែលត្រូវបានជំទាស់នោះ ពិតជាបានផ្តល់សំអាងហេតុ បញ្ជាក់ពីមូលហេតុដែល ស.ច.ស បានបដិសេធមិនស្តាប់ចម្លើយសាក្សីទាំងនោះ។ ជាការពិត សំអាងហេតុមួយក្នុងចំណោមសំអាងហេតុទាំងនោះ បង្កើតបានជាមូលដ្ឋានសម្រាប់ដើមបណ្តឹងឧទ្ធរណ៍យកមកធ្វើជាមូលដ្ឋានទីពីរក្នុងបណ្តឹងឧទ្ធរណ៍របស់ខ្លួន។ អង្គបុរេជំនុំជម្រះបដិសេធមូលដ្ឋាននេះនៃបណ្តឹងឧទ្ធរណ៍ ប៉ុន្តែ សូមធ្វើការកត់សម្គាល់ថា ដើមបណ្តឹងឧទ្ធរណ៍

---

[១០៩] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៤៤-៤៩។

[១១០] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៤៥។

[១១១] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៤៧។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE C.C.C. C.E.T.C.

មិនបានផ្តល់ភស្តុតាងនៃទីកន្លែងរបស់សាក្សី ដែលខ្លួនបានអះអាងថា បានទទួលពីនាយកមជ្ឈមណ្ឌល DC-Cam នោះទេ។

## ឃ. មូលដ្ឋានទីបួននៃបណ្តឹងឧទ្ធរណ៍៖ ការបដិសេធមិនត្រឹមត្រូវ ទៅលើសំណើ ព្រោះថាការស្តាប់ចម្លើយបុគ្គលដែលស្នើឡើងនោះ នឹងមិនជួយដល់កិច្ចស៊ើបសួរ

៤១. ផ្អែកលើមូលដ្ឋានទីបួននៃបណ្តឹងឧទ្ធរណ៍ ដើមបណ្តឹងឧទ្ធរណ៍អះអាងថា ដីកាសម្រេចដែលត្រូវបានជំទាស់ធ្វើឡើង ដោយផ្អែកទៅលើការបកស្រាយមិនត្រឹមត្រូវទៅលើច្បាប់ជាធរមាន នៅពេល ស.ច.ស បដិសេធសំណើសុំស្តាប់ចម្លើយសាក្សីពីការរៀបការដោយបង្ខំ ដោយផ្អែកលើមូលដ្ឋានមិនត្រឹមត្រូវដែលថា ការស្តាប់ចម្លើយបុគ្គលដែលស្នើឡើងទាំងនោះ នឹងមិនជួយដល់កិច្ចស៊ើបសួរឡើយ ដោយហេតុថាព័ត៌មានមាននៅក្នុងសំណុំរឿងរួចហើយ[១១២]។ ដើមបណ្តឹងឧទ្ធរណ៍អះអាងថា ស.ច.ស មិនត្រូវបានចងកាតព្វកិច្ចដោយការកំណត់បទចោទរបស់សហព្រះរាជអាជ្ញានៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទីបួននោះទេ ពីព្រោះថា ស.ច.ស ត្រូវសម្រេចជាមុនសិនទៅលើការកំណត់បទចោទសមស្របនៅក្នុងដីកាដំណោះស្រាយរបស់ខ្លួន។ ដើមបណ្តឹងឧទ្ធរណ៍អះអាងថា ស.ច.ស មិនទាន់បញ្ជាក់ថាតើ ឧក្រិដ្ឋកម្មណាមួយដែលខ្លួន "មានបំណងដាក់បញ្ចូលអង្គហេតុដ៏ច្រើនសន្ធឹកសន្ធាប់នៃ (តួយ៉ាង) ការរៀបការដោយបង្ខំ" ទៅក្រោមបទឧក្រិដ្ឋណាមួយនៅឡើយ[១១៣]។ ដើមបណ្តឹងឧទ្ធរណ៍អះអាងថា ខ្លួនបានស្នើឱ្យមានការចោទប្រកាន់ជនត្រូវចោទផ្ទួនគ្នាពីបទ (ប៉ុនប៉ង)រំលោភសេពសន្ថវៈ ដាក់ជាទាសករ(ផ្លូវភេទ) (ប៉ុនប៉ង)ធ្វើឱ្យមានផ្ទៃពោះដោយបង្ខំ និងការរៀបការដោយបង្ខំ ដែលជាបទឧក្រិដ្ឋជាក់លាក់។ ដើមបណ្តឹងឧទ្ធរណ៍អះអាងផងដែរថា "វាអាចជាផ្នែកមួយនៃការវាយប្រហារយ៉ាងទូលំទូលាយ ឬមានលក្ខណៈជាប្រព័ន្ធ ជាអំពើតែមួយ ឬក៏ជាការវាយប្រហារទូលំទូលាយ ឬជាប្រព័ន្ធដោយខ្លួនវាផ្ទាល់"[១១៤]។ ដើមបណ្តឹងឧទ្ធរណ៍អះអាងថា មានតែតាមរយៈការស្តាប់ចម្លើយសាក្សី និងជនរងគ្រោះបន្ថែមប៉ុណ្ណោះ ដែលអាចបង្ហាញថា ការរៀបការដោយបង្ខំមិនមែនជាបទឧក្រិដ្ឋមួយ

[១១២] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៥០-៥៩ និងជើងទំព័រ ៣៥ ដោយយោងទៅលើដីកាដែលត្រូវបានជំទាស់ កថាខណ្ឌ ១៦។

[១១៣] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៥៤។

[១១៤] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៥៤-៥៥។

ដាច់ចេញដោយឡែកពីគេតែឯង ដែលបានប្រព្រឹត្តនិងរៀបចំដោយកម្មាភិបាលម្នាក់ៗនោះ ប៉ុន្តែបានកើតឡើងទំនងជាផ្នែកមួយនៃប្រព័ន្ធដែលមានពាសពេញប្រទេស"[១១៥]។

៤២. អង្គបុរេជំនុំជម្រះយល់ឃើញថា ការចោទប្រកាន់របស់ដើមបណ្តឹងឧទ្ធរណ៍ ដោយផ្អែកលើមូលដ្ឋាននេះ ខ្វះភាពច្បាស់លាស់។ ជាបឋម ការចោទប្រកាន់នេះលើកឡើងម្តងទៀតថា សហព្រះរាជអាជ្ញាមានសិទ្ធិដាច់ណាត់ក្នុងការកំណត់នូវវិសាលភាពនៃកិច្ចស៊ើបសួរ។ បន្ទាប់មក ដើម-បណ្តឹងឧទ្ធរណ៍ហាក់ដូចជា ច្របាច់បញ្ចូលគ្នារវាងលក្ខខណ្ឌកំណត់តាមច្បាប់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងអង្គហេតុដែលត្រូវមានដើម្បីបញ្ជាក់ពីធាតុផ្សំនៃឧក្រិដ្ឋកម្មចំបងនេះ។ ហេតុដូច្នេះដើមបណ្តឹងឧទ្ធរណ៍ធ្វើមិនត្រឹមត្រូវ ដោយអះអាងថា ស.ច.ស មានកំហុសដោយមិនស៊ើបអង្កេត "ថាតើការរៀបការដោយបង្ខំ គឺជាការវាយប្រហារយ៉ាងទូលំទូលាយ ឬ មានលក្ខណៈជាប្រព័ន្ធប្រឆាំងនឹងប្រជាជនស៊ីវិល ដូច្នោះមែនដែរឬទេ"[១១៦]។ អង្គបុរេជំនុំជម្រះច្រានចោលមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍នេះ។

## ង. មូលដ្ឋានទីប្រាំនៃបណ្តឹងឧទ្ធរណ៍៖ ការបដិសេធមិនត្រឹមត្រូវលើអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមួយរូប

៤៣. ដោយផ្អែកលើមូលដ្ឋានទីប្រាំនៃបណ្តឹងឧទ្ធរណ៍នេះ ដើមបណ្តឹងឧទ្ធរណ៍ចោទប្រកាន់ថា ដីកាសម្រេចដែលត្រូវបានជំទាស់នោះ ធ្វើឡើងដោយផ្អែកលើការសន្និដ្ឋានមិនត្រឹមត្រូវយ៉ាងច្បាស់ក្រឡែតលើអង្គហេតុ ក្នុងការសម្រេចបដិសេធអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមួយរូប[១១៧] ដោយឈរលើមូលដ្ឋានថា ដើមបណ្តឹងឧទ្ធរណ៍មិនបានបង្ហាញឱ្យច្បាស់ថាតើការចោទប្រកាន់នោះ អាចស្ថិតនៅក្នុងវិសាលភាពនៃការស៊ើបអង្កេតបានដោយរបៀបណា[១១៨]។ ដើមបណ្តឹងឧទ្ធរណ៍លើកទឡ្ហីករណ៍ថា នៅក្នុងចម្លើយសាក្សីរបស់មជ្ឈមណ្ឌលDC-Cam សាក្សី

---

[១១៥] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៥៧។

[១១៦] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៥៩។

[១១៧] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៦០-៦២ ដោយយោងទៅលើ [redacted]។

[១១៨] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៦០ និងជើងទំព័រ ៤៤ ដោយយោងទៅលើដីកាដែលត្រូវបានជំទាស់ កថាខណ្ឌ ៧។



PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE

រៀបរាប់ ថាខ្លួនរស់នៅជាមួយឪពុកម្តាយនៅក្នុងខេត្តព្រៃវែង ថា ឪពុករបស់គាត់ គឺជាជនជាតិវៀតណាម ថា ឪពុករបស់គាត់ត្រូវបានគេយកទៅ ហើយមិនឃើញត្រឡប់មកវិញទេ ហើយថាខ្លួនគាត់ (សាក្សី) បានឮថា ឪពុកនោះត្រូវបានចាប់ខ្លួន និងសម្លាប់។ យោងតាមដើមបណ្តឹងឧទ្ធរណ៍ អង្គហេតុទាំងនេះពិតជាស្ថិតនៅក្នុងកថាខណ្ឌទី៦៩នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ម្ពៃមែនដែលក្នុងនោះរៀបរាប់ពីខេត្តព្រៃវែង ថាជាខេត្តមួយក្នុងចំណោមខេត្តចំនួនពីរដែលបក្សកុម្មុយនីស្តកម្ពុជាអនុវត្តគោលនយោបាយកម្ចាត់ប្រជាជនវៀតណាម[១១៩]។

៤៤. សំណើទីមួយយោងទៅលើសេចក្តីដកស្រង់ចំនួនបីទំព័រ ដែលដកចេញពីចម្លើយសាក្សីរបស់មជ្ឈមណ្ឌល DC-Cam បកប្រែពីភាសាខ្មែរទៅភាសាអង់គ្លេស ដើម្បីគាំទ្រសំណើសុំស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជាថ្មី។ សំណើនោះអះអាងថា បុគ្គលដែលត្រូវបានស្នើឱ្យស្តាប់ចម្លើយសារជាថ្មី បាននិយាយថា ឪពុករបស់គាត់ត្រូវបានគេយកទៅ ហើយ "មិនបានឃើញត្រឡប់មកវិញទេ"[១២០]។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ឯកសារនេះមិនមានរៀបរាប់ពីឪពុករបស់អ្នកដាក់ពាក្យសុំនោះថា ជាជនជាតិវៀតណាមទេ (បើទោះជាអង្គបុរេជំនុំជម្រះយល់ឃើញថា ឈ្មោះរបស់គាត់នៅលើឯកសារអាចបញ្ជាក់ថា គាត់គឺជាជនជាតិវៀតណាមក៏ដោយ)។ ឯកសារនោះក៏មិនបញ្ជាក់ ថាតើការចាប់ខ្លួនរបស់ឪពុកគាត់ធ្វើឡើងនៅពេលណា និងនៅទីកន្លែងណាដែរ។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា តាមពាក្យបណ្តឹងឧទ្ធរណ៍ ដើមបណ្តឹងឧទ្ធរណ៍យោងទៅលើចម្លើយសាក្សីពីរបានមកពី DC-Cam[១២១] ដែលខុសពីចម្លើយសាក្សីដែលផ្តល់ឱ្យ ស.ច.ស ក្នុងការគាំទ្រសំណើទីមួយ។ អង្គបុរេជំនុំជម្រះយល់ឃើញថា ដើមបណ្តឹងឧទ្ធរណ៍មិនបានអះអាងនៅក្នុងសំណើទីមួយថា ការបាត់ខ្លួននោះស្ថិតនៅក្នុងវិសាលភាពដែលមាននៅក្នុងកថាខណ្ឌទី៦៩ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទេ។ ដើមបណ្តឹងឧទ្ធរណ៍ខកខានក្នុងការបង្ហាញថា ស.ច.ស មានកំហុសអង្គហេតុ ដោយ ស.ច.ស សន្និដ្ឋានថា ព័ត៌មាននៅ

---

[១១៩] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៦២។

[១២០] សំណើសុំទីមួយ ជើងទំព័រ ៧៣ ដោយយោងទៅលើចម្លើយសាក្សីរបស់ DC-Cam ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០០ លេខ ERN (ភាសាអង់គ្លេស) 00332650។

[១២១] បណ្តឹងឧទ្ធរណ៍ ជើងទំព័រ ៤៥ ដោយយោងទៅលើចម្លើយសាក្សីរបស់ DC-Cam ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០០ លេខ ERN (ភាសាខ្មែរ) 00033536 និង ERN (ភាសាខ្មែរ) 0003540។

ក្នុងសំណុំរឿងមិនបានបង្ហាញឱ្យច្បាស់ ថាតើការចោទប្រកាន់ទាំងនោះស្ថិតនៅក្នុងវិសាលភាពនៃកិច្ចស៊ើបសួរឬទេ។ ហេតុដូច្នេះ មូលដ្ឋានទីប្រាំចុងក្រោយនេះ ត្រូវបានច្រានចោល។

**ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆ័ន្ទ៖**

១. **ទទួលយក**បណ្តឹងឧទ្ធរណ៍នេះ តាមទម្រង់ និង,

២. **ច្រានចោល**បណ្តឹងឧទ្ធរណ៍នេះ ចាត់ទុកថាឥតបានការ។

**ភ្នំពេញ ថ្ងៃទី ២១ ខែកក្កដា ឆ្នាំ ២០១០**

**នៅក្រុមអង្គបុរេជំនុំជម្រះ** **ប្រធាន**

**Rowan DOWNING** **នេយ ថុល** **Catherine MARCHI-UHEL** **ហួត វុទ្ធី** **ប្រាក់ គឹមសាន**